# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

&Y'

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

## និក្ខេបបទ

# ស្ថានភាពក្នុងការរៀន និងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅមធ្យមសិក្សា ករណីសិក្សា: ស្រុកកៀនស្វាយ

The Situation of Learning and Teaching Physical Education and Sport

Case Study: Kein Svay Dicstrict


**ដោយ**/by

**លុយ គឹមសាន**

LUY KIMSAN


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៨**


**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

&Y'

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

## ស្ថានភាពក្នុងការរៀន និងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅមធ្យមសិក្សា ករណីសិក្សា: ស្រុកកៀនស្វាយ

## The Situation of Learning and Teaching Physical Education and Sport Case Study: Kein Svay Dicstrict

**ដោយ**/by

**លុយ គីមសាន**

**LUY KIMSAN**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖ ជំទាវបណ្ឌិត បណ្ឌិត ឃួនវិច្ឆិកា**

**សាស្ត្រាចារ្យដឹកនាំរង៖ លោក ប៊ូ ប៊ុន្លួន**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦២៩ **អយក.** ប្រក

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ រីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត ស៊ិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ស្ថានភាពក្នុងការរៀននិងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅកម្រិតមធ្យមសិក្សាក្នុងស្រុកកៀនស្វាយ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានអប់រំគឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បាន ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទ ស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នក និពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

**លុយ គឹមសាន**

# លិខិតបញ្ជាក់

លោកជំទាវបណ្ឌិត **ឃួន វិច្ឆិកា** ជាសាស្ត្រាចារ្យដឹកនាំ

លោក **ប៊ូ ប៊ុន្នន** ជាសាស្ត្រាចារ្យដឹកនាំរង

*សូមបញ្ជាក់ និងទទួលស្គាល់ថា*

**លោក លុយ គឹមសាន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពក្នុងការរៀន និងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅកម្រិតមធ្យមសិក្សា ក្នុងស្រុកកៀនស្វាយ**"ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

......................................

**លោកជំទាវបណ្ឌិត ឃួន វិច្ឆកា**

អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ

....................................

**លោក ប៊ូ ប៊ុន្នន**

អនុប្រ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និង អង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) Cambodia International Education Support Foundation ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រង អប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែក គ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយ ហត់ឡើយ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតដល់លោកជំទាវ**បណ្ឌិតឃួន ទិទ្ធិភា** ដែលតែងតែចំណាយពេលវេលាមកពន្យល់ខ្ញុំបាទគ្រប់ជំហានទើបធ្វើឲ្យការស្រាវជ្រាវរបស់ខ្ញុំនាពេលកន្លងមក ទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអរគុណដល់លោកសាស្ត្រាចារ្យជំនួយលោក **ម៉ូ ម៉ុន្តន** និងលោក**ជី សាវីន** រួមទាំងមិត្តរួមជំនាន់ទី៦ទាំងអស់ដែលតែងតែផ្តល់ជាគំនិតល្អៗ និងកម្លាំងចិត្ត តាមរយៈការចែករំលែក ចំណេះដឹង បទពិសោធន៍ ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឲ្យការស្រាវជ្រាវនេះ មានភាពងាយស្រួល។

បន្ថែមពីនេះទៀតខ្ញុំសូមថ្លែងអំណរគុណដល់ លោកឪពុក អ្នកម្តាយ បងប្អូន និងភរិយារបស់ខ្ញុំ ដែល បានផ្តល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញ និងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវ ការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។ ខ្ញុំក៏សូមឧទ្ទិសនូវស្នាដៃនៃការសិក្សាស្រាវជ្រាវនេះជូនចំពោះ លោកឪពុក លុយ សឿង ដែលបានបែកកាយទៅកាន់លោកខាងមុខហើយក្តី សូមឲ្យលោកទទួលបាននូវអ្វីដែល ជាការខិតខំបណ្តុះបណ្តាលកូនមានថ្ងៃនេះផងចុះ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធិពរជូនចំពោះ លោកជំទាវបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ ក្រុមគ្រួសារ និងភរិយាខ្ញុំបាទឲ្យជួបតែពុទ្ធទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

ការហ្វឹកហាត់អប់រំកាយ និងកីឡា គឺជាសិទ្ធិមូលដ្ឋានសម្រាប់ទាំងអស់គ្នា។ ជាទូទៅការអប់រំកាយ និងកីឡាជាធាតុសំខាន់នៃការអប់រំពេញមួយជីវិតនៅក្នុងប្រព័ន្ធអប់រំ។ ការអប់រំកាយនិងកីឡាផានាការអភិវឌ្ឍនិងរក្សាការពារកម្លាំងកាយ បញ្ញា ស្មារតី និងសីលធម៌របស់មនុស្សលោក។ ប្រទេសកម្ពុជាយើងសព្វថ្ងៃ បានយកចិត្តទុកដាក់ដល់វិស័យអប់រំកាយនិងកីឡាសំដៅលើកកម្ពស់សុខភាពនិងសុខុមាលភាពដល់ប្រជាជនគ្រប់រូប។ រាជរដ្ឋាភិបាលរៀបចំឲ្យមានបរិស្ថានល្អ ខ្យល់អាកាសបរិសុទ្ធ មានឧទ្យានបៃតង ទីធ្លាសម្រាប់លំហាត់ប្រាណនិងកីឡា ដើម្បីទ្រទ្រង់សុខភាពនិងសុខមាភាពដល់សិស្សានុសិស្សទាំងផ្លូវកាយនិងផ្លូវចិត្ត។

ការសិក្សាស្រាវជ្រាវមួយស្តីពី "ស្ថានភាពការរៀន និងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅមធ្យមសិក្សា" ត្រូវបានរៀបចំឡើងក្នុងគោលបំណងស្វែងរកឲ្យឃើញពីស្ថានភាព និងកត្តាដែលប៉ះពាល់ដល់ការការអនុវត្តមុខវិជ្ជានេះ។ ការសិក្សាស្រាវជ្រាវប្រធានបទនេះផ្អែកលើទ្រឹស្តី និងឯកសាររបស់ស្ថាប័នពាក់ព័ន្ធផ្នែកអប់រំមួយចំនួនទាំងនៅក្នុងប្រទេស និងអន្តរជាតិ។ ការសិក្សានេះ ត្រូវបានអនុវត្តនៅអនុ/វិទ្យាល័យគោលដៅចំនួនប្រាំបី ក្នុងស្រុកកៀនស្វាយ រួមមាន វិទ្យាល័យជ័យវរ័ន្ទទី៧ វិទ្យាល័យហ៊ុនសែនសាន់នីវ៉ូសំពោងធំ វិទ្យាល័យហ៊ុនសែនសិរីជីដុះ អនុវិទ្យាល័យគរគីរ អនុវិទ្យាល័យរទាំង អនុវិទ្យាល័យឬស្សីស្រុក អនុវិទ្យាល័យគរគីរធំ និង អនុវិទ្យាល័យបន្ទាយដែក។ នៅទីនោះសិស្សានុសិស្សថ្នាក់ទី៧ ទី៨ ទី៩ ទី១០ ទី១១ និង ទី១២ ចំនួន ២០ក្រុម លោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាអប់រំកាយនិងកីឡា២១នាក់ និងគណៈគ្រប់គ្រងសាលាចំនួន៨នាក់ គឺជាមុខសញ្ញាគោលដៅ ដែលត្រូវសាកសួរដោយប្រើប្រាស់កម្រងសំណួរទៅតាមបែបគុណវិស័យដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវៈតើការអនុវត្តមុខវិជ្ជាអប់រំកាយ និងកីឡាមានស្ថានភាពដូចម្តេច និងតើកត្តាអ្វីខ្លះដែលធ្វើឲ្យអប់រំកាយ និងកីឡាមិនមានដំណើរការល្អនៅគ្រឹះស្ថានមធ្យមសិក្សា?

ជាលទ្ធផលឃើញថា អប់រំកាយ និងកីឡាមិនមានដំណើរការល្អទេ នៅក្នុងសាលារៀន រួមនឹងកត្តាសំខាន់ៗមួយចំនួនដែលប៉ះពាល់ដល់ការអនុវត្តនូវមុខវិជ្ជាអប់រំកាយ និងកីឡា។ ក្នុងនោះ រួមមាន ការមិនបានផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវកម្មវិធីសិក្សាអប់រំកាយ និងកីឡា ជាពិសេស មិនមានសៀវភៅសិក្សាគោលច្បាស់លាស់នៅតាមសាលារៀន។ មួយវិញទៀត ការខ្វះខាតសម្ភារៈអប់រំកាយ និងកីឡាដែលបម្រើដល់ការបង្ហាត់បង្រៀន ព្រមទាំងបរិស្ថានសាលារៀនមិន

អំណោយផលដល់ការអនុវត្តជាក់ស្តែង។ បន្ថែមជាងនេះ ការយល់ឃើញរបស់ គណៈគ្រប់គ្រង និងការអនុវត្តរបស់ពួកគាត់មិនសមាមាត្រនូវអ្វីដែលក្រសួងអប់រំ យុវជន និងកីឡាដាក់ឲ្យអនុវត្ត តាមសាលារៀន ។ ការមិនអនុវត្តទៅតាមតួនាទី និងភារៈកិច្ច របស់លោកគ្រូអ្នកគ្រូ ព្រមទាំង សិស្សានុសិស្សចំពោះអប់រំកាយ និងកីឡាផងដែរ។ លើសពីនេះទៀត ការមិនដាក់ជាមុខវិជ្ជានេះ នូវក្នុងការប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់ទី៩ និងទី១២ ព្រមទាំង បញ្ហាអាកាសធាតុ ប្រែប្រួល( ក្តៅ ហើយភ្លៀង ) ក៏ជាផ្នែកមួយ ដែលជះឥទ្ធិពលដល់ការអនុវត្តផងដែរ។

សរុបតាមលទ្ធផលខាងលើបានបង្ហាញថា កម្មវិធីសិក្សា បរិក្ខានិងបរិស្ថានសាលារៀនមិន អំណោយផល ការយល់ឃើញរបស់គណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងការមិន ដាក់បញ្ចូលក្នុងការប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់ទី៩ និង ថ្នាក់ទី១២ លើមុខវិជ្ជាអប់រំកាយ និង កីឡា រួមទាំងបញ្ហាប្រធានស័ក ជាកត្តាដែលប៉ះពាល់ដល់ការប្រតិបត្តិលើមុខវិជ្ជានេះ ។ ជាទី បញ្ចប់ ដើម្បីឲ្យការអនុវត្តនូវអប់រំកាយ និងកីឡានៅមធ្យមសិក្សាមានភាពល្អប្រសើរជាងនេះ គប្បីមានការកែប្រែនូវហេដ្ឋារចនាសម្ព័ន្ធ និងចូលរួមយ៉ាងសកម្មពីគ្រប់សមាសភាពពាក់ព័ន្ធទាំង អស់។

## Abstract

Training physical education and sport is universally recognized as the basic for all human right to gain knowledge, skills, attitude, spirit, and morality for all people on the world. The government of Cambodia take action on physical education and sport to make Cambodian become healthy and healthy. The governments and The ministry of Education, Youth, and sport was prepared to have good environment , fresh air, greed place , and field free for exercise and sport for people to have both physical and emotional health .

A study on "Learning and teaching physical Education and sport at secondary and high school "was organized in order to find out the effectiveness of practicing this subject for all secondary and high school in Kein Svay District , Kandal Province.

This study is based on qualitative methods by interviewed principle of DMT, 7 school principals, 21 sport teachers, and 20 group of students to collect the data base on the questionnaire research "what are the factors that make physical Education and sport don't run smoothly at school ".

Study result show that there were some signification to make this subject didn't run smoothly at school. First, Leaking information of implement sport program, curriculum and no basic text book for all sport teachers. Second, leaking of sport materials, school implements, and school environment to support on this subject. The perspective of principle, physical education and sport teachers, and students are the factors to make this situation happen like this. Moreover, base the result from research Shaw that physical education and sport was not used on national examination for grade 9 and grade 12 and this is the factor which let 'people think negative on this subject. The last point, was the weather because all sport activities practiced outside without roof. The climate change all the time and blocked physical education and sport subject.

Summery, to make physical education and sport more practicing we have to adopt sport curriculum, sport text book. The school implements and school environment must develop. The changing critical thinking of principles, teachers, and students on the subject are very important. Last point, we should use in examination.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..... i

លិខិតបញ្ជាក់ ..... ii

សេចក្តីថ្លែងអំណរគុណ ..... iii

មូលន័យសង្ខេប ..... iv

Abstract ..... vi

ជំពូកទី១ ..... 6

សេចក្តីផ្តើម ..... 6

១.១- លំនាំបញ្ហានៃការស្រាវជ្រាវ ..... 6

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..... 7

១.៣ គោលបំណងនៃការស្រាវជ្រាវ ..... 8

១.៤ សំណួរស្រាវជ្រាវ ..... 8

១.៥ វិធីសាស្ត្រស្រាវជ្រាវ ..... 9

១.ការជ្រើសរើសសំណាក ..... 9

២. ឧបករណ៍ស្រាវជ្រាវ ..... 9

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ..... 9

១.៧ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... 10

១.៧.១ វិសាលភាពនៃការស្រាវជ្រាវ ..... 10

១.៧.២ ដែនកំណត់នៃការស្រាវជ្រាវ ..... 10

១.៨ .រចនាសម្ព័ននៃការស្រាវជ្រាវ ........................................................................................10
ជំពូកទី២ ........................................................................................................................13
រំលឹកទ្រឹស្តី ........................................................................................................................13
២.១ ប្រវត្តិអប់រំកាយ ...........................................................................................................13
២.២ ទស្សនៈទានស្តីពីការសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា ..........................................................14
២.៣ ព័ត៌មានទូទៅអំពីការសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា ..........................................................16
២.៤. កំណែរទម្រង់ និងផែនការតាមអនុវិស័យឆ្នាំ២០១៤ - ២០១៨ របស់ក្រសួងអប់រំ យុវជន និង កីឡា...........................................................................................................................17
ក.កំណែទម្រង់វិស័យអប់រំ ...................................................................................................17
ខ.ផែនការតាមអនុវិស័យឆ្នាំ២០១៤ - ២០១៨ ..........................................................................18
ក.សារតា.........................................................................................................................18
ខ.វត្ថុបំណងគោលនយោបាយ.................................................................................................19
គ.សកម្មភាពគោលនយោបាយ ...............................................................................................19
ឃ. យុទ្ធសាស្ត្រ...................................................................................................................20
ង.សូចនាករផលសម្រេច ( សាធារណៈ និងឯកជន) ....................................................................20
ច. កម្មវិធី និងសកម្មភាព .....................................................................................................20
២.៥ និយមន័យពាក្យគន្លឹះ៖......................................................................................................20
២.៦ អត្ថន័យអប់រំកាយ និង កីឡា ............................................................................................21
២.៦.១ អត្ថន័យអប់រំកាយ និងកីឡាសម្រាប់សិស្សានុសិស្ស ..........................................................21
២.៦.២ អត្ថន័យអប់រំកាយ និងកីឡាសម្រាប់សង្គម ......................................................................22

២.៧ កម្មវិធិសិក្សា និងសៀវភៅសិក្សាគោលអប់រំកាយ និងកីឡា ......................................23
២.៨.ការអភិវឌ្ឍកម្មវិធីសិក្សា........................................................................................24
២.៩.សារៈសំខាន់នៃសៀវភៅសិក្សាគោល ......................................................................25
២.១០ . របាយម៉ោងសិក្សា និងរបាយពិន្ទុ.........................................................................26
២.១១.កម្មវិធីសិក្សាលម្អិតអប់រំកាយ និងកីឡា ( ថ្មី ) .......................................................28
២.១២. កម្មវិធីប្រកួតកីឡាសម្រាប់សិស្សនិស្សិត...............................................................31
២.១៣ ស្ថានភាពគ្រូអប់រំកាយ និងកីឡា ...........................................................................31
ជំពូកទី៣ ......................................................................................................................49
វិធីសាស្ត្រស្រាវជ្រាវ........................................................................................................49
៣.១ គម្រោងវិភាគ..............................................................................................................49
៣.២ វិធីសាស្ត្រនៃការស្រាវជ្រាវ...........................................................................................49
៣.២.១ វិធីសាស្ត្រប្រមូលទិន្នន័យ ........................................................................................50
ក.ទិន្នន័យចម្បង៖ ..........................................................................................................50
ខ.ទិន្នន័យមានស្រាប់ .....................................................................................................50
៣.២.២ ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ ..............................................................................50
៣.២.៣ វីធីសាស្ត្រជ្រើសរើសភាគសំណាក ............................................................................51
៣.២.៤ វិធីសាស្ត្រប្រមូលទិន្នន័យ ........................................................................................51
ជំពូកទី៤ ......................................................................................................................53
លទ្ធផល និងការពិភាក្សា...............................................................................................53
១.សេចក្តីផ្តើម ................................................................................................................53

I.កម្មវិធីសិក្សា............................................................................................................56

II.បរិក្ខានិងបរិស្ថានសាលារៀន ...........................................................................................57

III. ទស្សនៈរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស.....................60

ក.គណៈគ្រប់គ្រងសាលា...............................................................................................60

ខ.គ្រូបង្រៀន ..................................................................................................................61

គ. សិស្សានុសិស្ស..........................................................................................................63

IV.ការមិនដាក់បញ្ចូលអប់រំកាយ និងកីឡាក្នុងការប្រលងថ្នាក់ជាតិ ......................................64

V. បញ្ហាប្រធានស័ក ..........................................................................................................66

សន្និដ្ឋាន និងសូមនូមពរ ...................................................................................................68

៥.១.សន្និដ្ឋាន និងសមណ្ណមពរ ...........................................................................................68

៥.២.សូមណ្ណមពរ...................................................................................................................69

៥.២.១. ក្រសួងអប់រំ យុវជន និងកីឡា......................................................................................69

៥.២.២.នាយកសាលា ...........................................................................................................70

៥.២.៣. លោកគ្រូ អ្នកគ្រូអប់រំកាយ និងកីឡា.........................................................................70

៥.២.៤. សូមណ្ណមពរសម្រាប់ការសិក្សាបន្ត.............................................................................70

ឯកសារយោង..................................................................................................................71

ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា ....................................73

ឧបសម្ព័ន្ធទី ៣៖..............................................................................................................87

១-គណៈកម្មការមេប្រយោគ..................................................................................................87

២-គណៈកម្មការការពារនិក្ខេបបទ ........................................................................................88

# ជំពូកទី១

# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហានៃការស្រាវជ្រាវ

កម្ពុជាបានឆ្លងកាត់សង្គ្រាមស៊ីវិលជាងពីរទសវត្សន៍ ដោយបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសង្គមយ៉ាងធ្ងន់ធ្ងរទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងធនធានមនុស្ស។ ស្ថិតក្នុងស្ថានភាពនៃសាកលភាវូបនីយ៍កម្មបច្ចុប្បន្ន ជំរុញឲ្យកម្ពុជារិតតែមានការខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនលើគ្រប់វិស័យ ក្នុងនោះវិស័យអប់រំកាយ និងកីឡាបានរួមចំណែកកសាងសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយសមធម៌ ទាមទារឲ្យប្រជាជនមានចំណេះដឹងខ្ពស់ វប្បធម៌ជ្រៅជ្រះ ជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរម្យនាទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារប្រកបដោយនិរន្តរភាព។ ការប្រកួតកីឡាបានជំរុញឲ្យប្រទេសនីមួយៗដាក់ទុនវិនិយោគដើម្បីលើកកម្ពស់និងអភិវឌ្ឍគុណផលកីឡានៃវិញ្ញសាដែលមានសក្តានុពលសំដៅបានភាពជោគជ័យក្នុងការប្រកួតជាអន្តរជាតិ។ ប្រការនេះបានជួយលើកតម្កើងអត្តសញ្ញាណជាតិនិងកិត្យានុភាពជាតិ។ តាមស្មារតីនេះ វិស័យអប់រំកាយ និងកីឡាបានរួមចំណែកលើកកម្ពស់សុខភាព និងសុខមាភាពរបស់សិស្ស និសិត្ស និងប្រជាជនគ្រប់រូប និងបានកាត់បន្ថយភាពអសកម្មផ្សេងៗក្នុងសង្គមជាអាទិ៍ការប្រើប្រាស់គ្រឿងញៀណជាដើម។

អនុលោមតាមមាត្រា៦៥នៃរដ្ឋធម្មនុញព្រះរាជាណាចក្រកម្ពុជាដែលចែងថា" រដ្ឋយកចិត្តទុកដាក់លើវិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពប្រជាពលរដ្ឋខ្មែរគ្រប់រូប "។ក្នុងយុទ្ធសាស្រ្តចតុកោណរបស់រដ្ឋាភិបាល ស្តីពីការអប់រំ រួមនឹងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ គោលដៅអភិវឌ្ឍសហស្សវត្សន៍កម្ពុជា ផែនការយុទ្ធសាស្រ្តវិស័យអប់រំ នឹងឯកសារអន្តរជាតិពាក់ព័ន្ធនានាជាភស្តុតាងដើម្បីឆ្លើយតបទៅនឹងការរីកចំរើនរបស់វិស័យអប់រំកាយ និងកីឡា រដ្ឋាភិបាលបានរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា សំដៅកសាងធនធានមនុស្សឲ្យមានសុខភាពល្អ សមត្ថភាពនិងសីលធម៌ខ្ពស់ សមស្របតាមបរិបទកម្ពុជា រួមចំណែកអភិវឌ្ឍប្រទេសជាតិប្រកបដោយនិរន្តរភាព។

ជាពិសេសនៅឆ្នាំ២០២៣ខាងមុខប្រទេសកម្ពុជាយើងនឹងរៀបចំធ្វើជាម្ចាស់ផ្ទះកីឡាស៊ីហ្គេមលើប្រភេទវិញ្ញាសាប្រកួតកីឡាច្រើនប្រភេទ ដែលធ្វើឲ្យរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្រ្ត និងការធ្វើកំណែទម្រង់លើវិស័យអប់រំកាយ និងកីឡាយ៉ាងខ្លាំងខ្លាដោយមានការបើកសាលាបណ្តុះបណ្តាលកម្រិតថ្នាលគ្រប់ប្រភេទកីឡា និងមានការប្រកួតកីឡាគ្រប់លំដាប់ថ្នាក់ក្នុងនោះវិស័យអប់រំកាយ និងកីឡានៅសាលារៀនបានដើរតួនាទីយ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាលសិស្សានុសិស្សឲ្យស្របនិងកំណែទម្រង់របស់រដ្ឋាភិបាលដើម្បីឆ្ពោះទៅស៊ីហ្គេមដោយភាពជោគជ័យ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

អប់រំកាយ និងកីឡាគឺជាមុខវិជ្ជាក្នុងចំណោមមុខវិជ្ជាគោលជាច្រើន ដែលត្រូវបានយកមកបង្ហាត់បង្រៀននៅក្នុងកម្មវិធីសិក្សារបស់សាលារៀន និងមានគុណតម្លៃអប់រំជាច្រើន។ នៅក្នុងមុខវិជ្ជាអប់រំកាយ និងកីឡា សិស្សានុសិស្សអាចរៀនមិនត្រឹមតែជំនាញ និងចំណេះដឹងកីឡានោះទេ ថែមទាំងគុណតម្លៃវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាតាមរយៈការពន្យល់ណែនាំបែបមនោសញ្ចេតនា និងបែបអប់រំ ដែលជាគុណតម្លៃដ៏សំខាន់ក្នុងការរស់នៅក្នុងសង្គម។ ដូច្នេះវាមិនផ្តោតលើការឈ្នះ ឬការចាញ់នោះទេ ដោយវាបានចូលរួមចំណែកដល់ប្រសិទ្ធភាពញាណដឹងចលករចិត្តវិជ្ជា និងធនធានសង្គម ប្រែក្លាយជាពលរដ្ឋល្អ។ អប់រំកាយនិងកីឡាគឺជាមុខវិជ្ជាដែលសិស្សានុសិស្សអាចទទួលបានសមាសភាគមនុស្សដ៏សំខាន់ក្នុងការប្រើប្រាស់មនុស្សដ៏ថ្កុំថ្កើងធូរផង់ និងប្រកបដោយសុខមាលភាពតាមរយៈសកម្មភាពលេងកម្សាន្តជាមួយមិត្តភ័ក្តិជាច្រើន។ ជាឧទាហរណ៍ សិស្សានុសិស្សអាចទទួលបានជំនាញថ្មីៗនៃកីឡានីមួយៗ ការកត់សម្គាល់ពីសមត្ថភាពរបស់ខ្លួន និងបង្កើនលទ្ធភាពតាមរយៈអប់រំកាយ និងកីឡា ដើម្បីទទួលបានលទ្ធផលនេះ គ្រូអាចរៀបចំលក្ខខណ្ឌល្បែងលំហាត់តាមសមត្ថភាព និងជំនាញរបស់សិស្សានុសិស្សហើយបង្កើតលំហាត់ដែលអាចឲ្យសិស្សានុសិស្សសប្បាយរីករាយក្នុងសកម្មភាពកីឡា និងសកម្មភាពរាង្គកាយ។ព្រោះតែសិស្សានុសិស្សអាចចូលរួមអនុវត្ត ឬក៏លេងល្បែងអាស្រ័យលើសមត្ថភាព និងបទពិសោធន៍ឈ្នះឬចាញ់របស់ខ្លួន ពួកគេអាចជួយគាំទ្រគ្នាទៅវិញទៅមកជាមួយនឹងអកប្បកិរិយាល្អនិងសាងទំនាក់ទំនងដ៏សមរម្យជាមួយអ្នកដ៏ទៃ។ បទពិសោធន៍ទាំងនេះ នឹង

នាំផ្លូវទៅរកទំនាក់ទំនង និងការរួបរួមនៅក្នុងក្រុមគ្រួសារ សាលារៀន និងសង្គម ហើយពួកគេអាចចូលរួមចំណែកដល់ការសម្រេចបាននូវធនធានដ៏សម្បូរបែប និងប្រកបដោយសុខុមាលភាព ល្អ។ *(កម្មវិធីលម្អិតអប់រំកាយ និងកីឡាសម្រាប់មធ្យមសិក្សាបឋមភូមិ ២០១៥)*

បើទោះបីជាអប់រំកាយ និងកីឡាមានគុណប្រយោជន៍ មានអ្នកចូលរួមហ្វឹកហាត់ជាច្រើន និងមានការរីកចម្រើនគ្រប់ទិសទី ជាពិសេសប៉ុន្មានឆ្នាំចុងក្រោយនេះយើងសង្កេតឃើញថាក្នុងស្រទាប់យុវវ័យដែលភាគច្រើនពួកគាត់គឺជាសិស្សានុសិស្សដែលកំពុងសិក្សាមានការផុសផុលក្នុងវិស័យកីឡាយ៉ាងណាក៏ដោយ ក៏យើងឃើញថាវិស័យអប់រំកាយ និងកីឡានៅក្នុងសាលារៀនមិនមានដំណើរការល្អទេ(*សន្និបាតអប់រំឆ្នាំ២០១៨*)។ ហេតុដូចនេះហើយបានជាយើងចង់សិក្សាស្វែងយល់ និងរកឲ្យឃើញពីស្ថានភាព និងកត្តានានាដែលធ្វើឲ្យមុខវិជ្ជានេះមិនមានដំណើរការល្អនៅក្នុងសាលារៀន។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងសំខាន់គឺ សិក្សាឲ្យឃើញពីស្ថានភាពនៃការអនុវត្ត និងស្វែងយល់ពីមូលហេតុដែលធ្វើឲ្យមុខវិជ្ជាអប់រំកាយ និងកីឡាមិនមានដំណើរការល្អនៅក្នុងសាលារៀន ផ្អែកតាមទស្សនៈអ្នកចូលរួមទាំងអស់ និងដើម្បីសិក្សាពីវឌ្ឍនភាព បញ្ហាប្រឈម និងរកបទពិសោធន៍ល្អៗក្នុងការជំរុញ និងការអភិវឌ្ឍមុខវិជ្ជានេះឲ្យមានសកម្មភាពផុសផុលនៅក្នុងសាលារៀន។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការរៀន និងបង្រៀនក្នុងដំណើរការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ជាពិសេសលើមុខវិជ្ជាអប់រំកាយ និងកីឡានៅមធ្យមសិក្សា អ្នកស្រាវជ្រាវបានចោទសួរដូចខាងក្រោម៖

តើស្ថានភាពនៃការអនុវត្តមុខវិជ្ជាអប់រំកាយនិងកីឡានៅស្រុកកៀនស្វាយមានលក្ខណៈដូចម្តេច?

តើកត្តាអ្វីខ្លះដែលធ្វើឲ្យមុខវិជ្ជាអប់រំកាយ និងកីឡាមិនមានដំណើរការល្អនៅក្នុងសាលារៀន?

## ១.៥ វិធីសាស្ត្រស្រាវជ្រាវ

### ១.ការជ្រើសរើសសំណាក

ការស្រាវជ្រាវនេះធ្វើឡើងទៅលើអនុវិទ្យាល័យចំនួន៥ និងវិទ្យាល័យចំនួន៣ក្នុងស្រុកកៀនស្វាយ ខេត្តកណ្ដាល។ ភាគសំណាកសម្រាប់ធ្វើការស្រាវជ្រាវនេះរួមមាន ៖ ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុកកៀនស្វាយ គណៈគ្រប់គ្រងសាលា ៨នាក់ លោកគ្រូ អ្នកគ្រូមុខវិជ្ជាអប់រំកាយ និងកីឡា ២១នាក់ និងក្រុមសិស្សានុសិស្សពីថ្នាក់ទី ៧ ដល់ ទី ១២ ចំនួន២០ក្រុម។

### ២. ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះប្រើប្រាស់កម្រងសំណួរដោយប្រើវិធីសាស្ត្របែបគុណវិស័យ ដោយ ប្រើប្រាស់សំណួរជាទម្រង់បើក ការសម្ភាសន៍ និងមានការសង្កេតសកម្មភាពក្នុងការបង្រៀន និងរៀនរបស់គ្រូ និងសិស្សក្នុងសាលាគោលដៅ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ទោះបីការសិក្សានេះ មិនផ្តោតគ្រប់ជ្រុងជ្រោយលើស្ថានភាពការរៀន និងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡា ក៏លទ្ធផលនៃការសិក្សានឹងរួមចំណែកក្នុងការផ្តល់ជាព័ត៌មានត្រឹមត្រូវសម្រាប់ការអនុវត្តវិស័យអប់រំកាយ និងកីឡា សម្រាប់កែសម្រួលបញ្ហាប្រឈមនានាដែលគ្រូកំពុងជួបប្រទះ រួមនឹងការយល់ដឹងពីមូលហេតុដែលធ្វើឲ្យមុខវិជ្ជានេះមិនមានដំណើរការល្អ និងមិនមានការចាប់អារម្មណ៍និងយកចិត្តទុកដាក់ឬចូលរួមដូចមុខវិជ្ជាផ្សេងៗទៀត។ជាពិសេសធ្វើឲ្យប្រសើរឡើង ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាពខ្ពស់ និងសមស្របទៅនឹងកាយសម្បទារបស់សិស្ស ដែលផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតនិងបរិបទសង្គម ក្នុងការអភិវឌ្ឍសមត្ថភាពសិស្ស។មួយវិញទៀតសម្រាប់ផ្តល់ជាឯកសារពិគ្រោះសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយៗ។ លើសពីនេះ ការស្រាវជ្រាវដើម្បីផ្តល់ព័ត៌មាន និងលើកជាសូមណ្ឌមពរដល់អ្នកពាក់ព័ន្ធនានា ជាពិសេសដើម្បីបញ្ចប់និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦។

## ១.៧ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៧.១ វិសាលភាពនៃការស្រាវជ្រាវ

វិសាលភាពនៃការស្រាវជ្រាវ គ្របដណ្តប់លើអនុវិទ្យាល័យ និងវិទ្យាល័យនានាក្នុងស្រុកកៀនស្វាយ ដែលមានគ្រូបង្រៀនចំឯកទេសមុខវិជ្ជាអប់រំកាយ និងកីឡា សិក្សាពីទស្សនៈរបស់គ្រូបង្រៀន សិស្សានុសិស្សឯកទេសអប់រំកាយ និងកីឡាកំពុងរៀន និងបង្រៀននៅអនុវិទ្យាល័យនិងវិទ្យាល័យបច្ចុប្បន្នលើស្ថានភាព បញ្ហាប្រឈមរបស់គ្រូ និងមូលហេតុដែលមុខវិទ្យានេះមិនមានដំណើរការល្អ ដោយសម្ភាសន៍គ្រូបង្រៀន នាយកសាលា សិស្សានុសិស្សគោដៅបន្ថែមលើចំនុចខាងលើ។

### ១.៧.២ ដែនកំណត់នៃការស្រាវជ្រាវ

អាស្រ័យដោយពេលវេលា ឯកសា និងធនធានមានកំណត់ ដូច្នេះការសិក្សាស្រាវជ្រាវនេះមិនអាចសិក្សាទៅដល់គ្រប់បញ្ហាទាំងអស់នោះទេ គឺយើងសិក្សាតែលើស្ថានភាព កត្តាដែលប៉ះពាល់ដល់មុខវិជ្ជាអប់រំកាយ និងកីឡា និងរកយុទ្ធសាស្រ្តក្នុងការលើកកម្ពស់ដល់មុខវិជ្ជាអប់រំកាយ និងកីឡាឲ្យមានដំណើរការកាន់តែល្អប្រសើរឡើងជាងនេះ។

## ១.៨ .រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជា ប្រាំជំពូកគឺ៖

*ជំពូកទី១* ជាសេចក្តីផ្តើម ដែលបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោតបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ។

ក្នុង*ជំពូកទីពីរ* អ្នកស្រាវជ្រាវនឹងលើកឡើងពីទ្រឹស្តីនានាដែលទាក់ទងនឹងចំណុចទាំងអស់ដែលបានចោទសួរក្នុងចំណោតបញ្ហា ជាពិសេសបានបង្ហាញពីព័ត៌មានទូទៅទាក់ទងទៅនឹងកម្មវិធីសិក្សា សៀវភៅសិក្សាគោលអប់រំកាយ និងកីឡា និយមន័យពាក្យគន្លឹះមួយចំនួន ស្ថានភាពគ្រូអប់រំកាយ និងកីឡា និងកម្រិតនៃការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា។

វិធីសាស្ត្រស្រាវជ្រាវ នឹងត្រូវបង្ហាញនៅក្នុង*ជំពូកទីបី* ។ វិធីសាស្ត្រជ្រើសរើសភាគសំណាក វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និងវិភាគទិន្នន័យដែលអាចនាំទៅដល់ការបកស្រាយទិន្នន័យ និងត្រូវពន្យល់នៅក្នុងជំពូកនេះ។

នៅក្នុង*ជំពូកទីបួន* អ្នកស្រាវជ្រាវនឹងលើកឡើងពីលក្ខណៈជាក់ស្តែងនៃលទ្ធផលដែលយើងបានធ្វើសិក្សាស្រាវជ្រាវតាមរយៈ ឯកសារស្រាវជ្រាវនានា លទ្ធផលនៃការសម្ភាសន៍ និងឆ្លើយតបក្នុងកម្រងសំណួរ ដើម្បីធ្វើការប្រៀបធៀបទៅនឹងទ្រឹស្តី ហើយឆ្លើយតបទៅនឹងចំណោទបញ្ហាដែលបានចោទសួរ ក្នុងគោលបំណងវិភាគរកឲ្យឃើញចំណុចខ្វះខាត ដើម្បីធ្វើការកែលម្អនូវវិធីសាស្ត្របង្ហាត់របស់គ្រូ បញ្ហាប្រឈមដែលគ្រូកំពុងជួបប្រទះ និងមូលហេតុដែលមុខវិជ្ជាអប់រំកាយ និងកីឡាមិនមានដំណើរការល្អនៅមធ្យមសិក្សា។

នៅក្នុង*ជំពូកទីប្រាំ* ដែលជាជំពូកចុងក្រោយ យើងខ្ញុំនឹងធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់នៃលទ្ធផលស្រាវជ្រាវដែលបានរកឃើញ នឹងលើកជាសូមណូមមពរទៅលើចំណុចដែលត្រូវកែលម្អឬចំណុចខ្វះខាតនានា។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១ ប្រវត្តិអប់រំកាយ

នៅឆ្នាំ១៧២៣ -១៧៩០ Johann Bernhard Basedow លោកជាអ្នកទីមួយដែលបានបង្ហាញពីសារៈសំខាន់នៃលំហាត់ប្រាណ ហើយបានទាមទាឲ្យសាលារៀនត្រូវមានឯកសណ្ឋានពិសេសសម្រាប់សិស្សានុសិស្ស ធ្វើការហ្វឹកហាត់ដើម្បីងាយស្រួលដល់ការធ្វើចលនា និងការបំលាស់ទី ដោយគ្មានដែនកំណត់។ ក្រោយមកត្រូវបានគេស្គាល់លោកថាជាមនុស្សសំខាន់ក្នុងការងារហាត់ប្រាណ។

នៅឆ្នាំ១៧៩៨ -១៨៦៦ ( Charles Beck ) ជាមិត្តភក្តិរបស់ លោក Johann Bernhard Basedow ហើយជាអ្នកប្រតិបត្តិតាមលោក ត្រូវបានគេជួលឲ្យបង្រៀនមុខវិជ្ជាអប់រំកាយ តែទម្រង់របៀបមុខវិជ្ជាកាយសម្ព័ន្ធរបស់ជនជាតិអាឡឺម៉ង់ ហើយបន្ទាប់ពីនោះមក លោកបានក្លាយជាគ្រូផ្លូវការទីមួយ ដែលបង្រៀនមុខវិជ្ជាអប់រំកាយ ក្នុងសហរដ្ឋអាមេរិច។

នៅឆ្នាំ១៨២៣ -១៨៦៦ លោក Diocletian Lewis គឺជាមនុស្សទីមួយដែលបានជំរុញសកម្មភាពអប់រំកាយ ឲ្យបានច្រើនផ្នែក ក្រៅពីល្បែងឯកជន ។ ចំពោះបុគ្គលលោកផ្ទាល់ចង់បានប្រព័ន្ធមួយដើម្បីបង្ការជម្ងឺខ្សោយកម្លាំង កាត់បន្ថយ ភាពឆាប់ចាស់ សារធាតុខ្លាញ់ កុំឲ្យធាត់ ភាពទន់ខ្សោយ និងដំណើរឆាប់ទ្រុឌទ្រោមរបស់ស្ត្រី។ ក្រោយមកលោកបានបង្កើតវិទ្យាស្ថានអប់រំកាយ និងកីឡាមួយជាផ្លូវការនៅ Boston សហរដ្ឋអាមេរិច។ លោកមានគំនិតច្នៃប្រឌិតកន្លែងហ្វឹកហាត់ ដោយយកបាវសណ្តែក និងដុំឈើមានទម្ងន់ធ្វើជាសម្ភារឧបទេស សម្រប់លើកយកកម្លាំងសាច់ដុំ និងបន្ទាប់ពីនោះមក លោកបានប្រើបទចម្រៀងប្រកបបញ្ចូលជាចង្វាក់ភ្លេង ជាមួយការធ្វើលំហាត់ប្រាណ ធ្វើឲ្យមានការទាក់ទាញ យ៉ាងខ្លាំងដល់សិស្ស និង មនុស្សគ្រប់មជ្ឈដ្ឋាន។

ឆ្នាំ១៨៤០ -១៩២៤ លោក Dudley Allen Sargent គឺជាមនុស្សដែលបានបង្កើតម៉ាស៊ីនជាង ៨០ គ្រឿង ប្រើខ្សែរ៉កជាច្រើន និង ដុំទម្ងន់ សម្រាប់ធ្វើជាសម្ភារឧបទេស។ លោកបានបង្កើតស្តង់ដាសម្រាប់ការវាស់វែងការលូតលាស់របស់មនុស្សតាមវ័យ( ដោយគិតចំនួន គិតថេរវេលា គិតប្រវែង គិតទម្ងន់ គិតល្បឿន ជាដើម) ដោយប្រើចំនួនមនុស្ស ចូលរួមហ្វឹកហាត់ ក្នុងករណីផ្សេងៗគ្នា។

## ២.២ ទស្សនៈទានស្តីពីការសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា

អប់រំកាយ និងកីឡាគឺជាផ្នែកសិក្សាផ្លូវការមួយនៃការសិក្សានៅតាមសាលារៀនដែលបានរៀបចំឡើងដើម្បីលើកកម្ពស់ ការអភិវឌ្ឍនូវចំនេះដឹង ជំនាញ អាកប្បកិរិយា ក្នុងការរស់នៅរបស់សិស្សប្រកបដោយសុខុមាលភាព ជាមួយការអនុវត្តនូវវិធីសាស្ត្រសមស្របនៃរាងកាយ( NASPE, 2012 )។ការហ្វឹកហាត់អប់រំកាយ និងកីឡា បានរចនាឡើង សម្រាប់ក្មេងៗ ដើម្បីអភិវឌ្ឍកាយសម្បទា ជំនាញចលនា អារម្មណ៍ ចិត្តគំនិត ប្រាជ្ញាស្មារតី និងសុខភាពរបស់សិស្សានុសិស្ស ( Robinson &Goodigy 2009)។

អប់រំកាយសម្របសម្រួលនូវការអភិវឌ្ឍសុខភាពរាងកាយ និងបណ្តុះនូវឥរិយាបទវិជ្ជមានក្នុងការលេងកីឡាសម្រាប់សិស្សានុសិស្សទាំងអស់គ្នា តាមរយៈការទទួលមេរៀនអប់រំកាយដ៏សមស្របតាមការវិវឌ្ឍរបស់ពួកគេ។សិស្សានុសិស្សអាចរីកចម្រើនលើការស្តែងចេញនូវការអប់រំប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សាមុខវិជ្ជាផ្សេងៗទៀត។ សិស្សានុសិស្សក៏អាចទទួលយកនូវច្បាប់ទម្លាប់ដែលត្រូវគោរពនៅក្នុងសង្គម ក៏ដូចជាទម្លាប់នៅក្នុងជីវភាពប្រចាំថ្ងៃប្រកបដោយសុខុមាលភាព និងសុវត្ថិភាព។ដូចដែលបានលើកឡើងខាងលើនេះអប់រំកាយ និងកីឡាចូលរួមចំណែកក្នុងការបណ្តុះបណ្តាលធនធានមនុស្សក្នុងការអភិវឌ្ឍប្រទេសជាតិ បង្កើនសមត្ថភាពដល់សិស្សានុសិស្សដើម្បីពួកគេមានលទ្ធភាពប្រើប្រាស់វានូវក្នុងជីវភាពរស់នៅក្នុងសាលារៀន និងរស់នៅក្នុងសង្គមប្រកបដោយដោយសុខុមាលភាព។ លើសពីនេះពួកគេអាចទទួលបានចំណេះដឹងចាំបាច់ក្នុងការចូលរួមសកម្មភាពរាងកាយផ្សេងៗដែលជួយដល់សិស្សានុសិស្សចេះប្រើគំនិតច្នៃប្រឌិត គិតពិចារណា និងវិភាគបញ្ហា ហើយប្រើប្រាស់ចំណេះដឹងដើម្បីដោះស្រាយបញ្ហាសម្រាប់ចូលរួមក្នុងសកម្មភាពកីឡា និងសកម្មភាពរាងកាយពេញមួយជីវិត។ សិស្សានុសិស្សទទួលបានជំនាញដ៏សមស្រប រីករាយជាមួយការលេងកីឡា និងសកម្មភាពរាងកាយ ដោយគិតពិចារណាទៅលើដំណាក់កាលវិវឌ្ឍន៍ និងសមត្ថភាពផ្ទាល់ខ្លួន ហើយអាចបញ្ចេញកលល្បិច និងយុទ្ធសាស្ត្រដ៏សមស្របសម្រាប់ដោះស្រាយបញ្ហារបស់ពួកគេក្នុងស្ថានភាពប្រចាំថ្ងៃ។បន្ថែមជាងនេះទៀត មុខវិជ្ជាអប់រំកាយ និងកីឡានៅសាលារៀនបានផ្តល់ដល់សិស្សានុសិស្សនូវគុណតម្លៃ និងឥរិយាបទវិជ្ជមានចំពោះសកម្មភាពរាងកាយ មានភាពទទួលខុសត្រូវក្នុងតួនាទីភារៈកិច្ច ចែករំលែកគំនិតយោបល់ ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពកីឡា និង

សកម្មភាពរាងកាយជាមួយមិត្តភក្តិ ដោយផ្អែកលើដំណាក់កាលវិវឌ្ឍន៍ និងលទ្ធផលរបស់ពួកគេ ក្នុងការរស់នៅប្រកបដោយ សុខុមាមាលភាព សុវត្ថិភាព និងជីវភាពដ៏រីករាយ។

សម្តេចតេជោ ហ៊ុន សែន ជំរុញឲ្យប្រជាពលរដ្ឋយកចិត្តទុកដាក់លើវិស័យកីឡា និងរួមគ្នាវិនិយោគវិស័យកីឡា ជាមួយក្រសួងអប់រំ (Video inside)
(ភ្នំពេញ)៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានបន្តជំរុញឲ្យយកចិត្តទុកដាក់បន្ថែមទៀត ទៅលើ វិស័យកីឡា ហើយក៏ត្រូវហ៊ានវិនិយោគលើវិស័យកីឡាជាមួយក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ជាមួយគ្នានោះ សម្តេចតេជោ ក៏បានអំពាវនាវដល់អាណាព្យាបាល យុវជន កុមារៗ ព្រមទាំងប្រជាពលរដ្ឋខ្មែរ ត្រូវរួមគ្នាលេង និងហាត់កីឡាយ៉ាងតិចឲ្យចេះមួយ ដើម្បីសុខភាព។

សម្តេចតេជោ ហ៊ុន សែន បន្ថែមថា ការជំរុញវិស័យកីឡា មិនមែនសម្រាប់តែការលើកស្ទួយវិស័យកីឡានោះទេតែត្រូវតែជំរុញ លើកទឹកចិត្ត ឲ្យវិស័យកីឡាជំនាញ និងវិស័យពាក់ព័ន្ធ បង្កើនការយកចិត្តទុកដាក់ ពង្រឹងប្រសិទ្ធភាពការងារកីឡាដើម្បីឆ្ពោះ ទៅគោលដៅជោគជ័យក្នុងការរៀបចំ ការប្រកួតកីឡាស៊ីហ្គេម លើកទី៣២ ឆ្នាំ២០២៣ ដែលកម្ពុជា ធ្វើជាម្ចាស់ផ្ទះ ។

*ថ្លែងនៅក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំសិក្សា ឆ្នាំ២០១៥-២០១៦ និងលើកទិសដៅ សម្រាប់ឆ្នាំសិក្សា ២០១៦-២០១៧ របស់ ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្រោមអធិបតីភាព សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧។*

សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍យ៉ាងដូច្នេះថា «បើយើងឲ្យយុវជន និងកុមារ លេងកីឡាកាន់តែច្រើនគឺល្អជាង អាឲ្យទៅធ្វើផ្តេសផ្តាស សេពគ្រឿងញៀន សុទ្ធចិត្តឲ្យញៀន នឹងកីឡា លេងកីឡា ប្រសើរជាងទៅញៀនថ្នាំ ឬដើរលេងផ្តេសផ្តាស មួយទៀតខ្ញុំឃើញថា កីឡានៅតាមសាលារៀនរបស់យើង មាន៣ប្រភេទកីឡាបាល់ទាត់ កីឡាបាល់ទះ និងកីឡាបាល់បោះ។ ហើយល្ងាចមិញ ក៏មានការប្រកួតដ៏អស្ចារ្យដែរ តែមិនមែនជាការប្រកួតទេ ជាការទាល់ដ៏ស្វាតស្វាងប្រទេសដែលមានប្រជាជន១៣០លាននាក់ និងប្រទេសដែលមានប្រជាពលរដ្ឋ ជាង១៥លាននាក់ ដោយសារប្រវត្តិកន្លងមក ឥណ្ឌា ទាត់ចូលកម្ពុជា ៦គ្រាប់ ប៉ុន្តែទាត់ពីម្សិលមិញប៉ុណ្ណឹងបានហើយ យ៉ាងណាយើងត្រូវការឲ្យ ឈ្នះលើកក្រោយទៀត។ កម្ពុជាពីមុន មិនដែលស្គាល់ពាក្យថា

ឈ្នះទេ ប៉ុន្តែអាលូវមានហើយ។ យើងត្រូវមានការវិនិយោគលើវិស័យកីឡានេះ ទាំងអស់គ្នា ក្នុងនឹងអាចមានសប្បុរសធម៌ខ្លះជួយក្នុងវិស័យកីឡា»។

ទាក់ទងនឹងវិស័យកីឡានេះដែរ **រដ្ឋមន្ត្រី ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងនៅក្នុងពិធីបិទសន្និបាតខាងលើថា ក្រសួងអប់រំ បានបន្តជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡា ជាពិសេសនៅតាមគ្រឹះស្ថានសិក្សា ក្រៅពីនោះ ក្រសួងក៏បានជំរុញការ បណ្តុះបណ្តាល ធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា ដោយពង្រីកថ្នាលឧបនិស្ស័យកីឡា និងបន្តកំណែទម្រង់ការប្រកួតកីឡាគ្រប់ប្រភេទ ដោយបន្តរៀបចំការប្រកួតកីឡា និងធ្វើប្រតិភូកម្មមុខងារ និងការផ្តល់ការគាំទ្រដល់សហព័ន្ធកីឡាជាតិចំនួន២១ ការអនុវត្តឲ្យបានពេញលេញសកម្មភាពអប់រំកាយ និងកីឡាតាមសាលារៀន ការពង្រឹងសកម្មភាពបង្កើតក្លឹបកីឡាជាដើម៕

*នៅរសៀលថ្ងៃពុធ ៥កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨នេះ* សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីបិទសន្និបាតលទ្ធផលការងារអប់រំឆ្នាំ(២០១៧-២០១៨) ដែលធ្វើឡើងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (សាលាតិចណូ)។នៅក្នុងឱកាសនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានផ្តល់នូវអនុសាសន៍សំខាន់ៗ ៥ចំនុច ក្នុងការអភិវឌ្ឍន៍វិស័យអប់រំឲ្យកាន់តែរីកចម្រើនបន្ថែមទៀតៈ

អនុវត្តឱ្យសកម្មលើការងារកីឡា ដោយត្រូវអភិវឌ្ឍ សមាគមកីឡាមហាជន និងក្រុមកីឡាសិស្ស-និស្សិត ពង្រឹង និង ពង្រីកសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា បង្កើនការយកចិត្តទុកដាក់ពង្រឹងប្រសិទ្ធភាពការងារកីឡាគ្រប់ប្រភេទ ដើម្បីឈានឆ្ពោះទៅទទួលបានជោគជ័យកុងការប្រកួតកីឡាសីហ្គេម លើកទី ៣២ នៅឆ្នាំ ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ។ (http://freshnewsasia.com/index.php/en/localnews/50551-video-inside-119.html)

## ២.៣ ព័ត៌មានទូទៅអំពីការសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា

ធម្មនុញ្ញអន្តរជាតិ ស្តីពីអប់រំកាយ សកម្មភាពរាងកាយ និងកីឡា (UNESCO 2015 បុព្វកថា ១៧ វិច្ឆិកា ២០១៥) បញ្ជាក់ថា រដ្ឋអំណាច នឹងការទទួលខុសត្រូវសម្រាប់អប់រំកាយសកម្មភាពរាងកាយ និងកីឡា ត្រូវតែបម្រុងទុកដោយមិនប្រកាន់ពូជសាសន៍ ភេទ អាយុ ពិការភាពឬក៏មូលដ្ឋានដ៏ទៃទៀតដើម្បីជំនះបាននូវការអនុវត្តផ្នែករាងកាយ។ ការណែនាំឲ្យស្គាល់ថា អប់រំកាយ

សកម្មភាពរាងកាយ និងកីឡាអាចនាំនូវអត្ថប្រយោជន៍បុគ្គល និងសង្គមជាច្រើនដូចជា សុខភាព ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ការជុំរុញភាពអង្គអាចរបស់យុវវ័យ ការផ្សះផ្សា និងសន្តិភាព។ ការលើកឡើងនូវគោលការសំខាន់ៗនៃអប់រំកាយ និងកីឡាគឺមានសារៈសំខាន់ដើម្បីផ្តល់សេចក្តីសង្ឃឹមដល់សក្តានុពលពេញលេញរបស់ពួកគេសម្រាប់គាំទ្រគុណតម្លៃដូចជា លេងដោយយុត្តិធម៌ ស្មើភាព ស្មោះត្រង់ ឧត្តមភាព លើកទឹកចិត្ត ការងារក្រុម ការគោរពច្បាប់ និងបទបញ្ញា ការគោរពខ្លួនឯង និងអ្នកដ៏ទៃ ស្មារតីសហគមន៍ និងសាមគ្គីភាព ព្រមទាំងការសប្បាយ និងភាពរីករាយ។ អប់រំកាយ សម្មភាពរាងកាយ និងកីឡា គួរតែស្វែងរកដើម្បីបង្កើតទំនាក់ទំនងខ្លាំងរវាងមនុស្ស សាមគ្គីភាព ការគោរពគ្នា និងការយល់ពីគ្នាទៅវិញទៅមក ព្រមទាំងការគោរពចំពោះសេចក្តីសុចរិតភាព និងសេចក្តីថ្លៃថ្នូរដល់មនុស្សគ្រប់រូប។

សេចក្តីប្រកាសធម្មនុញអន្តរជាតិដែលដាក់បញ្ចូលអប់រំកាយ និងកីឡានៅក្នុងសេវាអភិវឌ្ឍមនុស្ស និងចំណង់ចំណូលចិត្តអ្នកគ្រប់គ្នា ជាពិសេសរដ្ឋាភិបាល អង្គការអន្តរដ្ឋាភិបាល អង្គការកីឡា អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជំនួញ ប្រព័ន្ធផ្សព្វផ្សាយ អ្នកអប់រំ អ្នកស្រាវជ្រាវ អ្នកអាជីពកីឡា និងអ្នកជូលរួមទាំងអស់ដើម្បីប្រតិបត្តិចែកផ្សាយធម្មនុញនេះដល់អ្នកគ្រប់គ្នា។ រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា មាត្រាទី៦៥នៃច្បាប់អប់រំបានលើកឡើងថា៖រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងចាត់វិធានការគ្រប់បែបយ៉ាងជាជំហ៊ានៗ ដើម្បីឲ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។រដ្ឋបានយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

## ២.៤. កំណែទម្រង់ និងផែនការតាមអនុវិស័យឆ្នាំ២០១៤ - ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា

### ក.កំណែទម្រង់វិស័យអប់រំ

១. កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

២. ការពង្រាយគ្រូបង្រៀន

៣. កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន

៤. ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន

៥. ការងារអធិការកិច្ច

៦. ការវាយតម្លៃលទ្ធផលសិក្សា

៧. កំណែទម្រង់ការប្រឡងសញ្ញបត្រមធ្យមសិក្សាទុតិយភូមិ

៨. កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល

៩. ការសាងសង់អគារសិក្សា និងសៀវភៅសិក្សាគោល

១០. ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា

១១. ការលើកកម្ពស់វិស័យកីឡា

១២. ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន

១៣. ការអប់រំបច្ចេកទេស

១៤. ការបង្កើតសាលារៀនជំនាន់ថ្មី

១៥. ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា

**ខ.ផែនការតាមអនុវិស័យឆ្នាំ២០១៤ - ២០១៨**

១. អនុវិស័យ អប់រំកុមារតូច

២.អនុវិស័យ ការអប់រំនៅបឋមសិក្សា

៣. អនុវិស័យ ការអប់រំនៅមធ្យមសិក្សា និងអប់រំបច្ចេកទេស

៤.អនុវិស័យ ការអប់រំឧត្តមសិក្សា

៥.អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

៦.អនុវិស័យ ការអភិវឌ្ឍយុវជន

៧.អនុវិស័យ ការអប់រំកាយ និងកីឡា

**ក.សារតា**

អប់រំកាយនិងកីឡាជាសមាសធាតុសំខាន់មួយរបស់វិស័យអប់រំ ក្នុងការលើកកម្ពស់សុខភាពរួមចំណែកជំរុញការសិក្សា និងការអភិវឌ្ឍប្រទេសជាតិ។ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំសេចក្តីណែនាំស្តីពី ការហាត់អប់រំកាយ និងកីឡាក្នុងម៉ោងនិងក្រៅម៉ោងសិក្សា ការប្រកួតកីឡាថ្នាក់រាជធានី ខេត្ត ការប្រកួតជើងឯកគ្រប់ភូមិសិក្សា ការប្រកួតកីឡាមហាជនរាជធានី ខេត្តថ្នាក់ភូមិភាគ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ កសាង និងកែលម្អរហេដ្ឋារចនាសម្ព័ន្ធកីឡាក្នុងនិងក្រៅសាលារៀន និងបណ្តុះបណ្តាលធនធានមនុស្សឯកទេសអប់រំកាយ និងកីឡា។ ការអភិវឌ្ឍការងារអប់រំកាយ និងកីឡាសំដៅរួមចំណែកលើកកម្ពស់សុខុមាលភាពប្រជាជន ពង្រឹងសាមគ្គី

ភាព កីឡាកម្រិតខ្ពស់ និងត្រៀមលក្ខណៈសម្បត្តិឲ្យបានល្អ ដើម្បីចូលរួមនិងរៀបចំព្រឹត្តិការណ៍កីឡាធំៗជាលក្ខណៈអន្តរជាតិ។

បញ្ហាប្រឈមចំពោះមុខមានដូចជា កង្វះខាតធនធានមនុស្សលើការងារគ្រប់គ្រង ដឹកនាំ និងចូលរួមរៀបចំសម្រាប់ការប្រកួតលក្ខណៈជាតិនិងអន្តរជាតិ។កង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តឧបករណ៍ និងសម្ភារកីឡា សម្រាប់បម្រើឲ្យការហ្វឹកហ្វឺននិងការប្រកួតជាលក្ខណៈជាតិនិងអន្តរជាតិ កង្វះខាតឯកសារ លិខិតបទដ្ឋានគតិយុទ្ធក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា។ រចនាសម្ព័ន្ធនៃការប្រកួតមិនទាន់បានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិងបរិបទនៃការប្រកួតកីឡានៅក្នុងតំបន់។ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសាធារណៈនិងឯកជន មិនបានពេញលេញ និងល្អប្រសើរនៅឡើយ។ជាទូទៅ ការចូលរួមរបស់កីឡាករកម្ពុជាក្នុងការប្រកួតនៅលើឆាកអន្តរជាតិមិនទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយ។

### ខ.វត្ថុបំណងគោលនយោបាយ

- លើកកម្ពស់សិទ្ធ ផ្តល់ឧកាស និងបណ្តុះបណ្តាលវប្បធម៌អប់រំកាយ និងកីឡាដល់ប្រជាជនគ្រប់រូប
- បង្កើនលទ្ធផលកីឡាករ កីឡាការនី ដើម្បីដណ្តើមយកជ័យជំនះក្នុងការប្រកួតកីឡាអន្តរជាតិនានា
- លើកកម្ពស់អភិបាលកិច្ចនិងការគ្រប់គ្រងក្នុងការអប់រំកាយ និងកីឡា។

### គ.សកម្មភាពគោលនយោបាយ

- រៀបចំសេចក្តីណែនាំស្តីពី ការរៀបចំទីធ្លាសម្រាប់ការងារអប់រំកាយ និងកីឡា២០១៤
- រៀបចំសេចក្តីណែនាំស្តីពី ការងារបច្ចេកទេសអប់រំកាយ និងកីឡានៅឆ្នាំ២០១៤
- រៀបចំសេចក្តីណែនាំស្តីពី ការហាត់អប់រំកាយ និងកីឡានៅក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា
- រៀបចំសេចក្តីណែនាំស្តីពីការប្រកួតកីឡានៅតាមគ្រឹះស្ថានសិក្សា នៅឆ្នាំ២០១៤
- រៀបចំគោលនយោបាយកីឡាជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡានៅឆ្នាំ២០១៤
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងវិស័យកីឡាជាតិ នៅឆ្នាំ២០១៦

- រៀបចំផែនការគោលស្តីពីការអភិវឌ្ឍកីឡាទៅឆ្នាំ២០២៣
- រៀបចំសេចក្តីណែនាំស្តីពីការការពារតម្លៃសីលធម៌និងវិជ្ជាជីវៈក្នុងការធ្វើសកម្មភាពអប់រំកាយ និងកីឡា នៅឆ្នាំ២០១៥

**ឃ. យុទ្ធសាស្ត្រ**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បំពាក់ឧបករណ៍ និងសម្ភារកីឡា
- ស្រាវជ្រាវចងក្រងឯកសារស្តីពីអប់រំកាយ និងកីឡា
- ពង្រឹងការផ្សព្វផ្សាយព័តមានកីឡា
- លើកកម្ពស់តម្លៃសីលធម៌ និងវិជ្ជាជីវៈអប់រំកាយ និងកីឡាដើម្បីទាំងអស់គ្នា
- ពង្រឹងសហប្រតិបត្តិការ ការងារកីឡាទាំងអង្គការសង្គមកីឡាជាតិ និងអន្តរជាតិ
- លើកកម្ពស់ការបណ្តុះបណ្តាល ការហាត់ហ្វឹកហ្វឺន និងការអភិវឌ្ឍសមត្ថភាព
- អភិវឌ្ឍក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុទ្ធ និងយន្តការ។

**ង.សូចនាករផលសម្រេច ( សាធារណៈ និងឯកជន)**

- ចំនួនគ្រូអប់រំកាយ និងកីឡាបណ្តុះបណ្តាលក្នុងមួយឆ្នាំ១៥០នាក់
- ទីលានកីឡាចំនួន៤ ( ពហុកីឡាដ្ឋានជាតិ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា  កីឡាដ្ឋានខេត្តសៀមរាប) ត្រូវបានកែលម្អនៅត្រឹមឆ្នាំ២០១៨
- គ្រឹះស្ថានមធ្យមសិក្សាចំនួន ១០ មានទីលានបាល់ទាត់ ១៥ មានទីលានបាល់បោះ និង ២០មានទីលានបាល់ទះនៅត្រឹមឆ្នាំ២០១៨
- ចំនួនមេដាយមាសក្នុការប្រកួតកីឡាស៊ីហ្គេមកើនពី ៤ ដល់២០ នៅឆ្នាំ ២០១៨។

**ច. កម្មវិធី និងសកម្មភាព**

- ការងារកីឡាក្នុងគ្រឹះស្ថានសិក្សាៈ រៀបចំស្រាវជ្រាវចងក្រងសៀវភៅសិក្សា ឯកសារ និងកម្មវិធីសិក្សាអប់រំកាយ និងកីឡាសម្រាប់សិស្សនឹងគ្រូ នៅតាមគ្រឹះស្ថានសិក្សា។
- បំប៉នគ្រូអប់រំកាយ និងកីឡាតាមគ្រឹះស្ថានសិក្សា

## ២.៥ និយមន័យពាក្យគន្លឹះ

ការរៀនគឺជាលំនាំមួយដែលនាំឲ្យមានការផ្លាស់ប្តូរ ហើយការផ្លាស់ប្តូរនោះបានមកពីការអនុវត្ត ឬក៏បាមកពីបទពិសោធន៍ដែលអ្នករៀនបានជួបប្រទះ។ ការរៀនគឺជាការផ្លាស់ប្តូរអកប្បកិរិ

យា ឬឥរិយាបទជាវិជ្ជមានហើយជាអចិន្ត្រៃយ៍ ការរៀនគឺជាការផ្សារភ្ជាប់នូវបទពិសោធរបស់បុគ្គលម្នាក់ៗ ហើយការរៀននេះវាទាក់ទងទៅនឹងទេពកោសល្យ បញ្ញា ចិត្តចលករ ឬភាពឧស្សាហ៍ព្យាយាមរបស់ បុគ្គលម្នាក់ៗ(*នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា២០១៥*)។

ការបង្រៀន គឺនិយាយសំដៅដល់សកម្មភាព សម្រាប់សម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្តសិស្សានុសិស្សឲ្យព្យាយាមអនុវត្ត និងពង្រឹងចំនេះដឹងរបស់ខ្លួន។ ការបង្រៀនរួមមានកញ្ចប់សកម្មភាពមួយចំនួនរបស់គ្រូដូចជា ការពន្យល់ ការសួររកហេតុផល ការលើកទឹកចិត្ត ការដឹងសាវតារបស់សិស្ស ការប្រលង ឬការវាយតម្លៃអំពីការរីកចម្រើននៃការសិក្សារបស់សិស្ស។ល។ ក្រៅពីមានគរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកជំនាញដ៏ទៃទៀតដែរ ត្រូវបន្តអភិវឌ្ឍន៍សមត្ថភាពវិជាជីវៈរបស់ខ្លួនពេញមួយជីវិត(*នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា២០១៥*)។

វិធីសាស្ត្រ គឺជាគោលការណ៍ ឬបច្ចេកទេសដែលប្រើដោយគ្រូដើម្បីជួយដល់ការសិក្សារបស់សិស្ស។ វិធីសាស្ត្រនេះត្រូវបានកំណត់ដោយផ្តោតលើប្រធានបទដែលគ្រូបង្រៀន និងមួយផ្នែកទៀតដោយកម្រិតរបស់អ្នកសិក្សា។

កម្រឹតយល់ដឹង គឺសំដៅលើសមត្ថភាពក្នុងការចាប់យកអត្ថន័យ នឹងអាចបកស្រាយខ្លឹមសាមេរៀនបានបន្ទាប់ពីការពន្យល់ និងការបកស្រាយរបស់គ្រូ។

បញ្ហាបប្រឈម គឺជាអ្វីដែលថ្មី និងពិបាកដែលទាមទារឲ្យមានារខិតខំ និងការប្តេជ្ញា ចិត្តយ៉ាងខ្លាំង។(www.collinsdictionary.com/dictionary/english/challenge)

អប់រំកាយ និង កីឡា គឺសំដៅលើសកម្មភាពទាំងឡាយដែលជួយដល់ការអភិវឌ្ឍផ្នែករាងកាយ បញ្ញា ស្មារតី សម្របសម្រួលដល់រាងកាយកាន់តែប្រសើរឡើងដែលជួយដល់ការប្រកួតប្រជែងត្រឹមត្រូវច្បាស់លាស់និងសមស្របដល់ការលេងកីឡាផ្សេងៗ។(https://334edb.khedcity.net/doc/eng/framework1/pe.pdf).

## ២.៦ អត្ថន័យអប់រំកាយ និង កីឡា

### ២.៦.១ អត្ថន័យអប់រំកាយ និងកីឡាសម្រាប់សិស្សានុសិស្ស

**១.ឥរិយាបថ** ៖ ការអប់រំលើការស្លៀកពាក់ ការគោរពគ្នា ការនិយាយស្តីមានសុជីវធម៌ ភាពរហ័សរហួន ក្លាហាន។ ការសម្តែងអាកប្បកិរិយាសមរម្យ នៅពេលបង្រៀនសិស្សឲ្យលេងល្បែងណាមួយ គ្រូត្រូវអង្កេតលើសកម្មភាព កាយវិកា ការនិយាយស្តី ភាពស្មោះត្រង់ ការទទួលយកមតិល្អៗពីមិត្តភក្តិ និងបុគ្គលិកលក្ខណៈផ្សេងៗត្រូវតែមានការទទួលខុសត្រូវ។ និយាយដោយឡែក

គ្រប់ឥរិយាបថ ឲ្យស្ថិតក្រោមការត្រិះរិះពិចារណា និងសេចក្ដីវិនិច្ឆ័យល្អិតល្អន់ ដើម្បីបណ្ដុះចរិយាធម៌ ឬចរិយាសម្បត្តិជាខ្មែរ ដែលមានតម្លៃជាសាកល។

**២. ចំណេះដឹង៖** នូវពេលសិស្សបានលេងពីល្បែងមួយ ហើយពួកគេអាចយកឬទទួលបានបច្ចេកទេសថ្មីៗបន្ថែមទៀត ពីសកម្មភាព និងលំហាត់ថ្មីៗ ដោយផ្អែកលើការចងចាំ និងការអនុវត្តនូវវិធីសាស្ត្រនិងបច្ចេកទេសក្នុងការប្រកួតប្រជែងដោយភាពស្មើរគ្នា។

**៣.ជំនាញ** ៖ ក្រោយពីបានយល់ដឹង ពួកគេលេងបានត្រឹមត្រូវ ផ្ដោតលើភាពវៃឆ្លាតរបស់ខ្លួន ការធ្វើចលនា បំលាស់ទី ការចេះស្រែកហៅដៃគូ តាមការពេញចិត្ត ឬឱកាសហុចឲ្យដោយភាពចំណេញ លទ្ធផល និងសុវត្ថិភាព ហើយមានការសប្បាយរីករាយជាដើម ។ ម្យ៉ាងវិញទៀត បើគេអាចលេងបានល្អនោះមានន័យថា គេទទួលបានសម្ថភាពលើចលនារាងកាយ និងសម្ថភាពបច្ចេកទេស។

**៤.សហការណ៍ ៖** ការលេងល្បែងមួយនេះ ត្រូវលេងមួយក្រុមមានគ្នាច្រើននាក់ ដូច្នេះពួកគេចេះចែកតួនាទីគ្នាលេង ចេះស្រែកហៅគ្នា ធ្វើចលនាបានរហ័សរហួន និងចេះស្វែងរកឱកាសល្អដើម្បីសម្រេចគោលបំណងខ្លួន។ មានន័យថា ការលេងជាក្រុម ការទទួលជ័យជំនះជាក្រុម ចាញ់ជាក្រុម ដូច្នេះពួកគេត្រូវស្វែងយល់ពីគ្នា ចេះទំនាក់ទំនងគ្នា និងឯកភាពគ្នា រួមគ្នាគិតនិងចេះផ្ដល់មតិយោបល់គ្នាទៅវិញទៅមក ដើម្បីទទួលបានលទ្ធផលល្អតាមក្រុមរៀងៗខ្លួន។

## ២.៦.២ អត្ថន័យអប់រំកាយ និងកីឡាសម្រាប់សង្គម

ជំរុញឲ្យសិស្ស និស្សិត និងប្រជាជនចាប់អារម្មណ៍ ពេញចិត្តចូលរួមទស្សនា ឬចូលរួមធ្វើសកម្មភាពអប់រំកាយ ឬលេងកីឡាយ៉ាងសកម្ម ដោយសប្បាយរីករាយ។ ម្យ៉ាងទៀឲ្យពួកគេមានទម្លាប់លេងកីឡាជាប្រចាំ ឬចូលរួមគាំទ្រកីឡា និងបានចលនាឧបត្ថម្ភដល់កីឡា ហើយគោរពតាមលក្ខខណ្ឌ និងច្បាប់ល្បែង ដើម្បីសុខភាព ក្នុងគោលដៅឲ្យមានអាយុវែង ព្រមទាំងជួយអភិវឌ្ឍដល់សុខភាពសាធារណៈ ដើម្បីលើកកម្ពស់ជីវភាពគ្រួសារ និងសេដ្ឋកិច្ចជាតិ។

**សម្រាប់កម្រិតឯកត្តជន** ៖ បង្កើនសម្ថភាពផ្ទាល់ខ្លួន សុខភាពទូទៅ ចំណេះដឹងផ្ទាល់ខ្លួន បញ្ញាស្មារតី ភាពក្លាហាន ជាមនុស្សដែលមានទំនាក់ទំនងល្អផ្ដល់គុណតម្លៃគ្នាទៅវិញទៅមក។

**សម្រាប់កម្រិតជាតិ** ៖ ជួយដល់កំណើនសេដ្ឋកិច្ច ការលូតលាស់សង្គម ធ្វើឲ្យប្រសើរឡើងសុខភាពសាធារណៈ និងនាំឲ្យសហគមន៍ ឬជាតិសាសន៍ផ្សេងគ្នាដើរឆ្ពោះទៅមុខ ស្របជាមួយគ្នានឹងបង្កើតឲ្យមានទំនាក់ទំនងល្អ ចំពោះគ្នាទៅវិញទៅមក។

**សម្រាប់កម្រិតសកលៈ** វាមានពេលយូរអង្វែងលើការអភិវឌ្ឍសុខភាពសាធារណៈ បរិស្ថានមានទំនាក់ទំនងល្អ ផ្តល់តម្លៃដល់មនុស្សជាតិ ជាទូតសន្តិភាព និងពិភពលោកមានភាពតែមួយ។ *( គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា ឆ្នាំ២០១៥)*

## ២.៧ កម្មវិធីសិក្សា និងសៀវភៅសិក្សាគោលអប់រំកាយ និងកីឡា

កម្មវិធីសិក្សាគឺជាមុខវិជ្ជា "អចិន្ត្រៃយ៍" ដូចជាវេយ្យាករណ៍ អំណានវោហាសាស្ត្រ តក្កវិជ្ជា គណិតវិទ្យានិងជាសៀវភៅដ៏អស្ចារ្យនៃលោកខាងលិចដែលបានបញ្ចូល ចំណេះដឹងសំខាន់ៗ ហើយល្អបំផុត។កម្មវិធីសិក្សាគឺជាមុខវិជ្ជាទាំងឡាយដែលមានប្រយោជន៍បំផុតសម្រាប់ការរស់នៅក្នុងសង្គមសម័យបច្ចុប្បន្ន។កម្មវិធីសិក្សា គឺជាផែនការនៃការសិក្សាទាំងអស់ ដែលបានគ្រោងទុកសម្រាប់ សាលារៀន ប្រកបដោយការទទួលខុសត្រូវខ្ពស់។ កម្មវិធីសិក្សា គឺជាលទ្ធផលសរុបនៃបទពិសោធន៍ក្នុងការសិក្សាដែលបានផ្តល់ ដល់សិស្សដើម្បីឲ្យពួកគេអាចទទួលបាននូវបំណិនទូទៅ និងជំនាញនានាភាពនៃតំបន់(បរិបទ)ដែលត្រូវសិក្សារៀនសូត្រ ។ កម្មវិធីសិក្សាគឺជាអ្វីៗដែលសិស្សទទួលបានពីការងារដោយកុំព្យូទ័ររបស់ខ្លួន និងពី បណ្តាញនានាដូចជាអ៊ិនធឺណិត។ កម្មវិធីសិក្សាគឺជាចំណោទបញ្ហារបស់អ្នកជំនាញនិងការស្វែងយល់ពីទិដ្ឋភាពស្មុគស្មាញ នៃស្ថានភាពរស់នៅរបស់មនុស្ស។ Bonser (1920) បានឲ្យនិយមន័យថា "កម្មវិធីសិក្សា គឺជាបទពិសោធន៍ទាំងឡាយដែល អ្នកសិក្សារំពឹងទុកថានឹងទទួលបាននៅក្នុងសាលារៀន" Caswell and Campbell (1935)បានឱ្យនិយមន័យថា "កម្មវិធីសិក្សាគឺជាការផ្សំឡើងនូវបទ ពិសោធន៍ទាំងឡាយដែលអ្នកសិក្សាទទួលបានក្រោមការបង្ហាត់បង្រៀនរបស់គ្រូ" Smith, Stanley, and Shores (1957)បានឲ្យនិយមន័យថា "កម្មវិធីសិក្សាគឺជាការតំរៀប បទពិសោធន៍របស់សិស្សឬនិស្សិតតាមលំដាប់លំដោយដើម្បីអប់រំពួកគេឲ្យចេះពីរបៀបគិត និងរបៀបធ្វើសកម្មភាពនានា។

សន្ទានុក្រមអប់រំនៅឆ្នាំ១៩៥៩ បានផ្តល់និយមន័យកម្មវិធីសិក្សាចំនួនបីៈ
១.កម្មវិធីសិក្សា គឺជាការតម្រៀបមេរៀន ឬការតម្រៀបខ្លឹមសារមេរៀនទៅតាមលំដាប់លំដោយនៃមុខវិជ្ជាដែលត្រូវរៀនដើម្បីងាយស្រួលក្នុងការវាយតម្លៃការបញ្ចប់ការសិក្សារបស់សិស្ស ឬដើម្បីងាយស្រួលចេញវិញ្ញាបនបត្រឯកទេសជាក់លាក់ទៅលើមុខជំនាញដែលគេសិក្សា។ ២.កម្មវិធី សិក្សា គឺជាការរៀបចំខ្លឹមសារមេរៀនទូទៅមួយឬជាការរៀបចំសម្ភារបង្រៀនជាក់លាក់មួយដែលសាលាគួរតែផ្តល់ទៅឲ្យអ្នកសិក្សាដើម្បីឲ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ចប់ការ

សិក្សា ឬទទួលបានវិញ្ញាបនបត្រ ជំនាញឯកទេស ឬជំនាញវិជ្ជាជីវៈ ។ ៣.កម្មវិធីសិក្សាគឺជាបណ្តុំមុខវិជ្ជានិងបទពិសោធន៍ដែលអ្នកសិក្សាគួរតែទទួលបានក្រោមការបង្ហាត់បង្រៀនពីគ្រូ។ Gagne នៅក្នុងឆ្នាំ១៩៦៧ បានឲ្យនិយមន័យថា កម្មវិធីសិក្សាគឺជាការតម្រៀបខ្លឹមសារចំណេះដឹងទៅតាមលំដាប់លំដោយដើម្បីផ្តល់សមត្ថភាពចំណេះដឹងបន្ថែម ទៅលើអ្វីដែលអ្នកសិក្សាធ្លាប់មានពីមុនរួចមកហើយ។ Saylor និង Alexander នៅឆ្នាំ ១៩៧៤ បានឲ្យនិយមន័យថា កម្មវិធីសិក្សា គឺជាមធ្យោបាយដើម្បីសម្រេចគោលដៅធំៗ ហើយជាប់ទាក់ទងទៅនឹងវត្ថុបំណងច្បាស់លាស់ដែលគ្រឹះស្ថានសិក្សាផ្តល់ឲ្យអ្នកសិក្សានៃប្រទេស ណាមួយ។ Johoson នៅក្នុងឆ្នាំ ១៩៧៧ បានឲ្យនិយមន័យថា កម្មវិធីសិក្សា គឺជាការតំរៀបទៅតាមលំដាប់លំដោយនូវលទ្ធផលសិក្សាដែលបានគ្រោងទុក។

នៅឆ្នាំ២០០៦ក្រសួងអប់រំកាយ និងកីឡាបានចុះអនុស្សរណៈយោគយល់គ្នា( MOU) ជាមួយអង្គការ (JICA) បានសហការអង្គការបេះដូងមាស (HEARTS OF GOLD) បានអញ្ជើញសាស្ត្រាចារ្យជំនាញអប់រំកាយ និងកីឡាពីបប្រទេសជប៉ុនជួយសម្របសម្រួលអនុវត្តផ្ទាល់ជាមួយនាយកដ្ឋានអប់រំកាយ និងកីឡាសិស្សនិស្សិតដើម្បីសិក្សាស្រាវជ្រាវចងក្រងកម្មវិធិសិក្សា និងសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំកាយ និងកីឡានៅបឋមសិក្សា។

នៅឆ្នាំ២០១៥ដល់ឆ្នាំ២០១៨ក្រសួងអប់រំកាយ និងកីឡាបានចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយអង្គការ (JICA) បានសហការណ៍ជាមយយអង្គការបេះដូងមាស (HEARTS OF GOLD) បានអញ្ជើញសាស្ត្រាចារ្យជំនាញអប់រំកាយ និងកីឡាពីប្រទេសជប៉ុនជួយសម្របសម្រួលអនុវត្តផ្ទាល់ជាមួយនាយកដ្ឋានអប់រំកាយ និងកីឡាសិស្សនិស្សិតដើម្បីសិក្សាស្រាវជ្រាវចងក្រងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំកាយ និងកីឡានៅមធ្យមសិក្សា។

## ២.៨.ការអភិវឌ្ឍកម្មវិធីសិក្សា

ការអភិវឌ្ឍ និងការធ្វើនវកម្មកម្មវិធីសិក្សា កំពុងក្លាយជាជាការប្រឈមដែលមានការវិវត្តលឿនក្នុងសម័យបច្ចុប្បន្ន ដោយសាពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ប្រទេសជាច្រើននៅលើសកលលោក បានទទួលស្គាល់ថា អភិក្រម ឬ បាតុភូតនៃសង្គមបានផ្តោតទៅលើគម្រោងនៃកម្មវិធីសិក្សាថ្មីដែលមានលក្ខណៈទន់ភ្លន់។ ទស្សនវិជ្ជាថ្មីមានទំនោរកំណត់ បញ្ចូលលទ្ធផលសិក្សាជាគោលបំណងចំបងក្នុងការអភិវឌ្ឍកម្មវិធីសិក្សាថ្មី ។ បញ្ញាតិនៃកម្មវិធីសិក្សាបានធ្វើឲ្យមានការផ្លាស់ប្តូរទស្សនៈ គោលគំនិតគរុកោសល្យ និងវិធីសាស្ត្រ សម័យមុន ដោយប្រែ

ក្លាយពីការបង្រៀន មកជាការរៀនដោយសកម្មភាពសិស្សជាគោល ពីការផ្ទេរពុទ្ធិមកជាការស្ថាបនាពុទ្ធិដោយខ្លួនឯង និងអភិវឌ្ឍបំណិន សម្ថភាពសិស្ស ដើម្បីស្រលាញ់ការសិក្សាពេញមួយជីវិតព្រមទាំងធានានូវគុណភាពអប់រំសម្រាប់ទាំងអស់គ្នា។

ការវិវឌ្ឍខាងលើនេះឆ្ពោះទៅលើគុណភាពអប់រំ និងធ្វើឲ្យជីវិតរស់នៅកាន់តែល្អប្រសើរឡើងដោយបង្កើនការផ្សារភ្ជាប់ កម្មវិធីសិក្សាទៅនឹងជីវភាពប្រចាំថ្ងៃ។ ទំនោរនៃការអប់រំនៅកម្ពុជាមិនខុសពីទំនោរនៃការអប់រំ លើពិភពលោកទេ ព្រោះតំរូវការអភិវឌ្ឍសង្គមជាតិ ការរីកចំរើនផ្នែកសេដ្ឋកិច្ចមិនអាចខ្វះធនធានមនុស្សបានឡើយ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកែលម្អកម្មវិធីសិក្សា ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សាពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា អ្នកវិទ្យាសាស្រ្ត និងវិនិយោគគិនទាំងឡាយ។ បច្ចុប្បន្នរាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្រ្តចតុកោណ សំដៅអភិវឌ្ឍប្រទេសជាតិកាន់តែរីកចម្រើនលើគ្រប់វិស័យជាពិសេសការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ឯការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សជាតួនាទីរបស់ការងារអប់រំនៅក្នុងសង្គមជាតិយើង។ឈរលើគោលការខាងលើនេះក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការកែសម្រួលកម្មវិធីកម្រិតអប់រំមូលដ្ឋានចំណេះទូទៅ។

## ២.៩.សារៈសំខាន់នៃសៀវភៅសិក្សាគោល

ការអប់រំនៅប្រទេសកម្ពុជាមានការខ្វះខាតគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់នូវវីធីសាស្រ្តបង្រៀនថ្មីៗដែលសង្កត់ធ្ងន់ទៅលើការរៀនបែបសកម្ម។គ្រូបង្រៀនច្រើនតែមានទំនោផ្តោតការសង្កត់ធ្ងន់លើការទន្ទេញចាំមាត់ ហើយជាលទ្ធផលសិស្សានុសិស្សបច្រើនតែគ្មានសមត្ថភាពអាចផ្សារភ្ជាប់អ្វីដែលខ្លួនបានសិក្សាទៅនឹងការដោះស្រាយបញ្ហាប្រចាំថ្ងៃរបស់ខ្លួនបានឡើយ។ កុមារប្រហែលជាដឹងពីព័ត៌មានផ្សេងៗ ប៉ុន្តែជារឿយៗពួគគេមិនយល់ពីព័ត៌មានទាំងអស់នោះ ឬមិនដឹងពីរបៀបប្រើប្រាស់ព័ត៍ទាំងអស់នោះយ៉ាងដូចម្តេចនោះទេ។ ការផ្លាស់ប្តូរស្ថានភាពនេះ គឺជាបញ្ហាប្រឈមរយៈពេលវែងដែលទៀមទាការកែលម្អឡើងវិញនូវកម្មវិធីសិក្សា។

អន្តរាគមន៍មួយដែលអាចនាំមកនូវការផ្លាស់ប្ដូរដ៏ធំធេងគួឲ្យកត់សម្គាល់ដោយប្រើប្រាស់ពេលវេលាខ្លីសមគួរនោះ គឺសាលារៀនត្រូវមានសៀវភៅសិក្សាគោលដែលលើកកម្ពស់វិធីសាស្ត្របង្រៀន និងវិធីរៀនបែបថ្មី។ សៀវភៅទាំងនេះជួយសម្រួលគ្រូបង្រៀនតាមរយៈការផ្ដល់ឧទាហរណ៍ស្ដីពីវិធីសាស្ត្របង្រៀនថ្មីៗព្រមទាំងអនុញ្ញាតឲ្យសិស្សានុសិស្សអាចធ្វើអន្តរកម្មជាមួយព័ត៌មានជាមួយបានបើទោះបីជាគុណភាពនៃការបង្រៀននៅមានកម្រិតកដោយ។ បញ្ហាប្រឈមនៅក្នុងប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា គឺការធ្វើយ៉ាងណាដើម្បីផលិត និងចែកចាយសៀវភៅសិក្សាគោលដែលមានគុណភាពខ្ពស់ក្នុងចំនួនគ្រប់គ្រាន់ដែលឆ្លុះបញ្ចាំងនូវវិធីសាស្ត្របង្រៀន និង វិធីសាស្ត្ររៀនបែបថ្មី។

កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ត្រូវបានវាយតម្លៃជាប្រចាំ ដើម្បីធានាឲ្យបាននូវភាពសមស្របជាមួយស្ថានភាពនៃការអភិវឌ្ឍរបស់ប្រទេស។ ការពិនិត្យឡើងវិញជាប្រចាំទៅលើកម្មវិធីសិក្សានឹងអាចកំណត់នូវតម្រូវការថ្មីៗដែលត្រូវកែសម្រួលនូវកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលផងដែរ ដើម្បីឲ្យសៀវភៅសិក្សាឆ្លុះបញ្ចាំងកម្មវិធីសិក្សា ។ ការផ្ដល់សៀវភៅសិក្សាគោលសម្រាប់សិស្សានុសិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គឺជាអាទិភាពសំខាន់បំផុតក្នុងការរៀននិងបង្រៀន។ សៀវភៅសិក្សាគោល មានសារៈសំខាន់ជាពិសេសដែលអាចឲ្យអ្នកសិក្សាមានភាពឯករាជ្យជាក់លាក់មួយនៅក្នុងថ្នាក់រៀន ។ គ្រូបង្រៀនមួយចំនួនមិនមានសមត្ថភាពគ្រប់គ្រាន់ ( គុណវុឌ្ឍិពេញលេញ ) ក្នុងការបង្រៀនមុខវិជ្ជាឯកទេសទេ។ ដូចនេះសៀវភៅសិក្សាគោលដែលប្រកបដោយគុណភាពល្អ នឹងជួយដល់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ២.១០ . របាយម៉ោងសិក្សា និងរបាយពិន្ទុ

នៅក្នុងសេចក្ដីណែនាំស្ដីពី«ការអនុវត្តម៉ោងសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា ក្នុងម៉ោង និងក្រៅម៉ោងនៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា»ដែលមានការចុះហត្ថលេខាដោយលោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា គឺបានកំណត់ចំណុចសំខាន់ចំនួន៥ ដើម្បីឲ្យគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា ត្រូវអនុវត្ត ៖

ទី១-គ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា២ម៉ោងក្នុង១សប្តាហ៍ស្របតាមកម្មវិធីកំណត់ថ្នាក់ជាតិ ។

ទី២-គ្រឹះស្ថានបឋមសិក្សានិងមធ្យមសិក្សាត្រូវបំផុសនិងរៀបចំបង្កើតសមាគមន៍កីឡាឲ្យបានគ្រប់សាលាដើម្បីហាត់កីឡាក្រៅម៉ោងសិក្សាបន្ថែម ។

ទី៣-មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ត្រូវពង្រឹងសមាគមកីឡាសិស្ស និងធ្វើឲ្យដំណើរការសកម្មភាពហាត់កីឡាក្រៅម៉ោងសិក្សាគ្រប់ស្រុក ក្រុង ខណ្ឌ ឲ្យមានប្រសិទ្ធភាព ។

ទី៤-គណៈគ្រប់គ្រងសាលា និងក្រុមបច្ចេកទេសត្រូវពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំលើគ្រប់សកម្មភាពរៀននិងបង្រៀនរបស់គ្រូទទួលបន្ទុកថ្នាក់ និងគ្រូអប់រំកាយនៅក្នុងសាលារបស់ខ្លួន។

របាយម៉ោងសិក្សាអប់រំកាយ និងកីឡានៅកម្រិតមធ្យមសិក្សា ១ម៉ោងសិក្សាមានរយៈពេល ៥០ នាទី ត្រូវបានបែងចែកដូចក្នុតារាងខាងក្រោមៈ

| ថ្នាក់ទី | ម៉ោងសិក្សា |
|---|---|
| ៧ | ១ សប្តាហ៍ សិក្សា ២ ម៉ោង<br>២ម៉ោង x ៣៥ = ៧០ម៉ោង/១ឆ្នាំសិក្សា |
| ៨ | ១ សប្តាហ៍ សិក្សា ២ ម៉ោង<br>២ម៉ោង x ៣៥ = ៧០ម៉ោង/១ឆ្នាំសិក្សា |
| ៩ | ១ សប្តាហ៍ សិក្សា ២ ម៉ោង<br>២ម៉ោង x ៣៥ = ៧០ម៉ោង/១ឆ្នាំសិក្សា |
| ១០ | ១ សប្តាហ៍ សិក្សា ២ ម៉ោង<br>២ម៉ោង x ៣៥ = ៧០ម៉ោង/១ឆ្នាំសិក្សា |
| ១១ | ១ សប្តាហ៍ សិក្សា ២ ម៉ោង<br>២ម៉ោង x ៣៥ = ៧០ម៉ោង/១ឆ្នាំសិក្សា |
| ១២ | ១ សប្តាហ៍ សិក្សា ២ ម៉ោង<br>២ម៉ោង x ៣៥ = ៧០ម៉ោង/១ឆ្នាំសិក្សា |

រយៈពេលប្រលង និងរបបពិន្ទុ

| ល.រ | ថ្នាក់ | រយៈពេល(នាទី) | ពិន្ទុអតិបរមា |
|---|---|---|---|
| ១ | ៧ | ៥០ | ៥០ |
| ២ | ៨ | ៥០ | ៥០ |
| ៣ | ៩ | ៥០ | ៥០ |
| ៤ | ១០ | ៦០ | ៥០ |
| ៥ | ១១ | ៦០ | ៥០ |
| ៦ | ១២ | ៦០ | ៥០ |

*ចំពោះថ្នាក់ទី ៩និងទី១២ យកពិន្ទុប្រចាំខែ តែមិនយកពិន្ទុប្រលងឆមាសឡើយ។*

## ២.១១.កម្មវិធីសិក្សាលម្អិតអប់រំកាយ និងកីឡា ( ថ្មី )

### ក.សម្រាប់បឋមសិក្សាបឋមភូមិថ្នាក់ទី៧ ថ្នាក់៨និងថ្នាក់ទី៩

ក.១.បណ្តំមុខវិជ្ជា

- ភាពសមស្របនៃរាង្គកាយ
- អប់រំកាយជាមួយចង្វាក់ភ្លេង
- កីឡាប្រពៃណី
- អត្តពលកម្ម
- កាយសម្ព័ន្ធ
- ហែលទឹក
- ល្បែងបាល់

### ខ.សម្រាប់មធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ១១ និងទី១២

ខ.១.បណ្តំមុខវិជ្ជា

- ភាពសមស្របនៃរាង្គកាយ
- អប់រំកាយជាមួយចង្វាក់ភ្លេង
- កីឡាប្រពៃណី
- អត្តពលកម្ម
- កាយសម្ព័ន្ធ
- ហែលទឹក
- ល្បែងបាល់



## គ. ទម្រង់កិច្ចតែងការសម្រាប់កម្មវិធីសិក្សាថ្មី

| | | | | | |
|---|---|---|---|---|---|
| | | ថ្នាក់ទី: | | | មុខវិជ្ជា: |
| កាលបរិច្ឆេទ | | ថ្នាក់ | | ម៉ោងទី | នៃមេរៀន |
| ឈ្មោះគ្រូបង្រៀន | | | | | |
| សម្ភារឧបទេស | | | | | |
| សុវត្ថិភាព | | | | | |
| *វត្ថុបំណង*<br>ឥរិយាបថ:<br>ចំណេះដឹង:<br>ជំនាញ:<br>សហការ: | | | | | |
| *វាយតម្លៃ*<br>ឥរិយាបទ ចំណេះដឹង:<br>ជំនាញ សហការ: | | | | | |

| និតិវិធី | សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|---|
| *ជំហានទី១* | | | |
| *ជំហានទី២* | | | |
| *ជំហានទី៣* | | | |

| | | | |
|---|---|---|---|
| *ជំហានទី៤* | | | |
| *ជំហានទី៥* | | | |

## ២.១២. កម្មវិធីប្រកួតកីឡាសម្រាប់សិស្សនិស្សិត

តាមខ្លឹមសារក្នុងសេចក្តីណែនាំនេះ ក្រសួង អប់រំ យុវជន និងកីឡា មានការបើកទូលាយឲ្យសាលារៀននីមួយៗបង្កើតជាកម្មវិធីហ្វឹកហាត់ទៅលើប្រភេទកីឡាដែលខ្លួនអាចធ្វើទៅបាន ជាពិសេសគឺបាល់ទាត់ បាល់ទះ បាល់បោះ និងកីឡាអត្តពលកម្ម ដែលមាននៅក្នុងកម្មវិធីប្រកួតជើងឯករាជធានីខេត្តជើងឯកភូមិភាគ និងការប្រកួតជើងឯកទូទាំងប្រទេស។ លើសពីនេះជារៀងរាល់ឆ្នាំក្រសួង អប់រំ យុវជន និងកីឡា មានការប្រកួតកីឡាសម្រាប់សិស្សានុសិស្សជារៀនរាល់ឆ្នាំ ចាប់ពីថ្នាក់ស្រុក ខណ្ឌ ដើម្បីជ្រើសរើសក្រុមឆ្នើមទៅបន្តថ្នាក់ខេត្ត រីឯថ្នាក់ខេត្តប្រកួតជ្រើសរើសក្រុមខ្លាំងទៅបន្តនៅទូទាំងប្រទេស។

## ២.១៣ ស្ថានភាពគ្រូអប់រំកាយ និងកីឡា

គ្រូអប់រំកាយ និងកីឡាតាមស្រុកនីមួយៗនៃខេត្តកណ្តាល

| ល.រ | ស្រុក | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ខ្សាច់កណ្តាល | ១៦ | ១ | ១៧ | |
| ២ | អង្គស្នួល | ៩ | ៣ | ១២ | |
| ៣ | កណ្តាលស្ទឹង | ២៧ | ១៦ | ៤៣ | |
| ៤ | ពញាឮ | ១៦ | ០ | ១៦ | |
| ៥ | មុខកំពូល | ២១ | ១០ | ៣១ | |

| | | | | | |
|---|---|---|---|---|---|
| ៦ | ល្វាឯម | ៤ | ១ | ៥ | |
| ៧ | កៀនស្វាយ | ២០ | ៩ | ២៩ | |
| ៨ | លើកដែក | ១៦ | ៥ | ២១ | |
| ៩ | ស្អាង | ១១ | ១ | ១២ | |
| ១០ | កោះធំ | ៩ | ០ | ៩ | |
| ១១ | តាខ្មៅ | ១៩ | ៣ | ២២ | |

ផែនទីសិក្សាស្រុកកៀនស្វាយ




## ២.១៤. ការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា

ដូចគ្នាទៅនឹងមុខវិជ្ជាដទៃទៀតដែរ ការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡាចែកចេញជាពីរកម្រិត។ កម្រិតទីមួយ គឺគ្រូអប់រំកាយ និងកីឡាកម្រិតមូលដ្ឋានដែលត្រូវបណ្តុះបណ្តាលរយៈពេលពីរឆ្នាំ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡារាជធានីភ្នំពេញ។ លក្ខខណ្ឌនៃការជ្រើសរើសសម្រាប់គរុសិស្សដែលត្រូវជ្រើសរើសឲ្យចូលរៀនក្នុងវគ្គបណ្តុះបណ្តាលនេះត្រូវ៖

១.បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ

២. បេក្ខជនទាំងពីរភេទត្រូវមានអាយុចាប់ពី ១៧ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង

៣. បេក្ខជនទាំងពីរភេទត្រូវនៅលីវរហូតដល់បញ្ចប់ការបណ្តុះបណ្តាល

៤. បេក្ខជនទាំងពីរភេទត្រូវមានសុខភាពល្អ កាយសម្បទាមាំមួន និងគ្រប់លក្ខណៈ (ត្រូវពិនិត្យកាយសម្បទាមុនពេលប្រឡង)ទីតាំងពិនិត្យសុខភាពស្ថិតនៅវិទ្យាស្ថានជាតិអប់រំកាយ និកីឡា

បេក្ខជនៈ នារី ត្រូវមានកម្ពស់ចាប់ពី ១.៥៥ម៉ែត្រ ឡើងទៅ

បេក្ខជនៈ បុរសៈ ត្រូវមានកម្ពស់ចាប់ពី ១.៦៥ ម៉ែត្រ ឡើងទៅ

បេក្ខជនដែលបានប្រឡងជាប់ ទទួលចំណាត់ថ្នាក់ពីលេខ ១ ដល់លេខ២៥ ចំនួន ២៥នាក់ ត្រូវបានជ្រើសរើសឲ្យរៀនកម្រិតបរិញ្ញាបត្រ រយៈពេល ៤ឆ្នាំ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។ ក្នុងករណីណាបេក្ខជនណាម្នាក់មិនចង់ជ្រើសរើសកម្រិតបរិញ្ញាបត្រ រយៈពេល ៤ឆ្នាំ បេក្ខជនលេខរៀងបន្ទាប់នឹងចូលមកជំនួស។

## ២.១៥.បរិក្ខារកីឡា

សម្ភារឧបទេស គឺជាឧបករណ៍សម្រាប់ជំនួយក្នុងការបង្រៀន និងរៀនអោយមានប្រសិទ្ធភាព។សម្ភារឧបទេស ទាំងនោះមានដូចជាៈ សៀវភៅ, ក្រដាស, ក្តារខៀន, រូបសំណាក, វត្ថុពិត, ឧបករណ៍បញ្ចាំងរូប, សោតទស្សន៍ (វិទ្យុ, ទូរទស្សន៍, ខ្សែភាពយន្ត...)។ ប៉ុន្តែបើយើងនិយាយពីសម្ភារឧបទេសសម្រាប់អប់រំកាយ និងកីឡាវិញរួមមានបាល់ទាត់ បាល់ទះ បាត់បោះ កោណកញ្ចែរ ដុំដែក ខ្សែពួរ របា ក្រូណូម៉ែត្រ ......។

ការបង្រៀនវាមានការលំបាកណាស់ក្នុងការពន្យល់មេរៀនដោយប្រើតែពាក្យសំដីមួយមុខដើម្បីអោយមនុស្សយល់ សូម្បីតែអ្នកនោះជាអ្នកជំនាញខាងនិយាយក៏ដោយ។ ផ្អែកលើការស្រាវជ្រាវដែលគេបានរកឃើញថាមនុស្សយើងអាចផ្តោតអារម្មណ៍មួយលើកៗ ទៅលើអ្វីមួយបានតែ ២៥ នាទីប៉ុណ្ណោះ។ តែប្រសិនបើមិនដូច្នោះ យើងក៏អាចបញ្ចូលគំនិតអ្វីមួយដែលជួយពញ្ញាក់ស្មារតីផងដែរ។ ដើម្បីឲ្យការសិក្សាបានដល់គោលដៅ គ្រូត្រូវសម្ភារឧបទេសគ្រប់គ្រាន់សម្ភារៈទាំងនោះជាជំនួយបន្ថែម ដើម្បីអោយការសិក្សាបានដល់គោលដៅ។ គ្រូណាក៏ដោយ ក៏ត្រូវការចាំបាច់ ដើម្បីហ្វឹកហាត់ខ្លួនឯងសិន មុននឹងប្រើប្រាស់ សម្ភារឧបទេសអ្វីមួយអោយបានត្រឹមត្រូវនោះ។.មុននឹងជ្រើសរើសសម្ភារឧបទេសដែលចាំបាច់ ហើយច្បាស់លាស់យកទៅបង្រៀនគឺត្រូវពិចារណាលើៈ

ការជ្រើសរើសសម្ភារឧបទេសៈសម្រាប់ប្រើប្រាស់ក្នុងមេរៀន យោងទៅតាមមុខវិជ្ជា, អត្ថន័យនៃមេរៀន, ហើយនិងគោលដៅនៃមេរៀន។ គ្រូត្រូវអភិវឌ្ឍន៍នូវយុទ្ធសាស្ត្រ ដែលជំរុញឲ្យសម្រេចបាននូវគោលដៅនៃមេរៀន។ យុទ្ធសាស្ត្រនោះ ត្រូវបានបង្កើតអោយចេញជារូបរាងឡើង ដោយផ្អែកទៅលើវិធីសាស្ត្រ និងសម្ភារឧបទេស សម្រាប់ផ្តល់ពត៌មាន។

មុខវិជ្ជាអប់រំកាយ និងកីឡា ជាមុខវិជ្ជាមួយដែលផ្តោតលើការអនុវត្តច្រើនជាងការបង្រៀននៅក្នុងថ្នាក់។ វាមិនខុសប្លែកពីមុខវិជ្ជាដ៏ទសទៀតទេដែលត្រូវការចាំបាច់នូវសម្ភារឧបទេសសម្រាប់ទ្រទ្រង់ក្នុងការបង្រៀនរបស់ខ្លួន។ ក្នុងការហ្វឹកហាត់ពិតជាត្រូវការចាំបាច់នូវសម្ភារច្រើនប្រភេទ ដើម្បីជាជំនួយដល់ការសម្រេចគោលដៅ នឹងបញ្ចប់ខ្លឹមសារមេរៀនបានដោយជោគជ័យ។








## ២.១៦.បរិស្ថានសាលា

ក្រសួងអប់រំយុវជន និងកីឡាបានយកចិត្តទុកដាក់លើការកែលម្អលើ ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទនិងគ្រប់កម្រិត បានសាងសង់សាលដំបូលទុកសម្រាប់ហ្វឹកហាត់កីឡាបាល់ទះ និង សាងសង់ទីលានកីឡាអត្តពលកម្មសិប្បនិម្មិតនៅក្នុងពហុកីឡាដ្ឋានជាតិ។ លើសពីនេះសាងសង់អគារសិក្សា អន្តេវាសិកដ្ឋាន និងសាលសម្រាប់ហាត់កីឡា នៅវិទ្យាស្ថានជាតិអប់រំ កាយ និងកីឡា។កសាងទីលានកីឡាក្នុងគ្រឹះស្ថានសិក្សា (កីឡាបាល់បោះ និងបាល់ទាត់)។ពិនិត្យតាមដាន និងវាយតម្លៃការជួសជុលទីលានកីឡា ការអភិវឌ្ឍសមាគមកីឡា និងការបំប៉នសមត្ថភាពគ្រូអប់រំកាយនិងកីឡា។ ជួសជុលទីលានកីឡាក្នុងគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា។សាងសង់មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡាឱ្យបានត្រឹមត្រូវតាមនិយាមបច្ចេកទេស និងបង្កើត មជ្ឈមណ្ឌលភូមិភាគ។ ទីលានកីឡានៅតាមគ្រឹះស្ថានសិក្សាបឋមសិក្សានិងមធ្យមសិក្សាត្រូវបានកែលម្អជាបន្តបន្ទាប់។

**យោងតាម សុន្ទរកថា និងសេចក្តីអត្ថាធិប្បាយរបស់ សម្តេចតេជោ ហ៊ុន សែន ក្នុងពិធីបិទសន្និបាត ក្រសួង អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៥-២០១៦ និងទិសដៅឆ្នាំ ២០១៦-២០១៧**

*ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយជាអនេក ដោយបានចូលរួមក្នុងពិធីបិទ «សន្និបាតបូកសរុបការងារ អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៥-២០១៦ និងលើកទិសដៅឆ្នាំសិក្សា ២០១៦-២០១៧» ដែលក្រសួង អប់រំ យុវជន និងកីឡា បានរៀបចំឡើងយ៉ាងឱឡារិក ក្នុងរយៈពេល ៣ ថ្ងៃមកនេះ។*

*ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះអង្គសន្និបាត ដែលមិនត្រឹមតែអាចពិនិត្យលទ្ធផល សម្រេចបានលើការងារអប់រំទាំងមូលប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ បានយល់ ជ្រួតជ្រាប និងបន្តចូលរួមអនុវត្តកម្មវិធីកែទម្រង់កាន់តែស៊ីជម្រៅ ក្នុងស្មារតីធ្វើឱ្យវិស័យអប់រំកម្ពុជាកាន់តែ មានការអភិវឌ្ឍ ឆ្លើយតបទៅនឹងបរិការណ៍ថ្មីៗ នៃសង្គម-សេដ្ឋកិច្ច ទាំងក្នុងតំបន់ និងពិភពលោក ក្នុង ខណៈដែលកម្ពុជាមានសុខសន្តិភាពពេញលេញ ស្ថិរភាព*

នយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រម ទាំងធានាបាននូវភាពសុខដុម និងប្រក្រតីភាព នៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

ជាការពិត វឌ្ឍនភាពនៃវិស័យអប់រំនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ គឺបានស្តែងចេញពីកិច្ច ខិតខំប្រឹងប្រែង និងកិច្ចសហការយ៉ាងជិតស្និទ្ធរបស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃក្រសួង អប់រំ យុវជន និងកីឡា សាស្ត្រាចារ្យ គ្រូបង្រៀន មាតាបិតាសិស្ស-និស្សិត សហគមន៍ និងអាជ្ញាធរដែនដី នៅទូទាំងប្រទេស ដែលតែងតែយកចិត្តទុកដាក់រួមចំណែកអភិវឌ្ឍវិស័យអប់រំ និងការកសាងធនធានមនុស្ស ប្រកបដោយស្មារតីទទួលខុសត្រូវតាមតួនាទី និងភារកិច្ចរៀងៗខ្លួន។ ទន្ទឹមនេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ ចំពោះដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានសហការ និងផ្តល់ការឧបត្ថម្ភគាំទ្រ ទាំងសម្ភារៈ ថវិកា ការជួយរៀបចំផែនការសកម្មភាព និងការជួយជ្រោមជ្រែងក្នុងការអនុវត្តសកម្មភាពការងារ ក្នុងវិស័យអប់រំ យុវជន និងកីឡា នាពេលកន្លងមក និងការបន្តគាំទ្រ អនុវត្តនៅពេលខាងមុខ។

ជារួម វិស័យអប់រំកាន់តែដើរតួនាទីសំខាន់ឡើង ក្នុងការរួមចំណែកដល់ការបង្កើនសក្តានុពលនៃស្រទាប់ យុវជនជំនាន់ថ្មី ឱ្យកាន់តែមានចំណេះដឹង កាន់តែមានសមត្ថភាពខ្ពស់ ក្នុងការចាប់ឱ្យយកការងារ បង្កើនភាពប្រកួតប្រជែង និងលើកកម្ពស់ជីវភាពគ្រួសារ ក៏ដូចជា រួមចំណែកដល់កិច្ចដំណើរការអភិវឌ្ឍន៍ ប្រទេសជាតិ ព្រមទាំងការពង្រឹងស្មារតី និងឆន្ទៈរួមរបស់ប្រជាជនឲ្យស្រឡាញ់ និងការពារថែរក្សានូវសុខ សន្តិភាព។ ក្នុងនោះ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់នៅគ្រប់កម្រិតសិក្សា និងការ ប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព គឺជាការចាំបាច់ និងត្រូវយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀត។ តាមរយៈនេះ ខ្ញុំសូមគាំទ្រចំពោះអភិក្រម និងវិធីសាស្ត្រថ្មីៗ ដូចមានក្នុងរបាយការណ៍បូកសរុប លទ្ធផលសន្និបាតរបស់ ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ក្នុងគោលដៅបង្កើនសមត្ថភាពភាពប្រកួតប្រជែងរបស់ប្រជាជនកម្ពុជា ក្នុងការចាប់យកកាលានុវត្តភាពថ្មីៗ ខណៈដែលកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងកិច្ចសមាហរណកម្ម ទាំងក្នុងកម្រិតតំបន់ និងពិភពលោក។

អនុវត្តឱ្យសកម្មលើការងារកីឡា ដោយត្រូវអភិវឌ្ឍសមាគមកីឡាមហាជន និងក្រុមកីឡាសិស្ស-និស្សិត អភិវឌ្ឍកម្មវិធីអប់រំកាយ និងកីឡា និងការហាត់ហ្វឹកហ្វឺនតាមលក្ខណៈជាតិ និងអន្តរជាតិពង្រឹង និងពង្រីកសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា។ ជាមួយនេះ ត្រូវខិតខំ

អនុវត្តគោល នយោបាយជាតិ ស្តីពីការអភិវឌ្ឍការអប់រំកាយ និងកីឡា ព្រមទាំងបំផុសស្មារតីមហាជន ពិសេសយុវជន យើងឱ្យបានចូលរួមគ្រប់ៗគ្នា។ ក្នុងនោះ ការជំរុញវិស័យកីឡា មិនមែនត្រឹមតែដើម្បីលើកកម្ពស់សុខុមាល ភាពប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងត្រូវជំរុញលើកទឹកចិត្តឱ្យវិស័យកីឡាជំនាញ និងស្ថាប័នពាក់ព័ន្ធ បង្កើនការយកចិត្តទុកដាក់ពង្រឹងប្រសិទ្ធភាពការងារកីឡា ដើម្បីឆ្ពោះទៅទទួលបានជោគជ័យ ក្នុងការរៀប ចំការប្រកួតកីឡាស៊ីហ្គេម (SEA Games) លើកទី ៣២ ឆ្នាំ ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះទៀត ផង។

## *រក្សាដីនៅតាមមូលដ្ឋាន ដើម្បីបណ្តុះបណ្តាលវិស័យកីឡា/ជក់លេងកីឡា ប្រសើរជាងជក់គ្រឿងញៀន*

ចំណុចនេះ ខ្ញុំអំពាវនាវមិនមែនគ្រាន់តែបញ្ហាទាក់ទងជាមួយចាងហ្វាង ឬក៏គ្រូប៉ុណ្ណឹងទេ ទាក់ទងទៅហ្នឹងការទទួលខុសត្រូវ(របស់)អាជ្ញាធរថ្នាក់ក្រោមជាតិ ហើយនឹងការចូលរួមនានាពីសប្បុរសជន និងពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។ បើនៅតាមមូលដ្ឋាន យ៉ាងហោចណាស់រក្សាបានដីទុកឲ្យបានធំ ដើម្បីជាផ្នែកនៃការបណ្តុះបណ្តាលវិស័យកីឡានេះ ហើយបើយើងឲ្យយុវជន និងកុមាររបស់យើង លេងកីឡាកាន់តែច្រើន អារឿងផ្តេសផ្តាស (ដូចជា)សេពគ្រឿងញៀនស្អីៗនេះ វាកាត់បន្ថយទៅឯងតែម្តង ដោយសារតែជក់(នឹង)កីឡា។ សុខចិត្តឲ្យជក់(នឹង)កីឡា ឲ្យលេងកីឡា ប្រសើរជាងឲ្យទៅជក់គ្រឿងញៀន និងដើរលេងផ្តេសផ្តាស។

## *ក្រៅពីបាល់ទាត់ បាល់ទះ និងបាល់បោះ ត្រូវយកចិត្តទុកដាក់បង្កើតទីតាំងកីឡាកាយសម្ព័ន្ធ*

មួយទៀតខ្ញុំឃើញថា កីឡារបស់យើងច្រើនតែយកចិត្តទុកដាក់នៅតាមសាលាតែបីផ្នែកទេ បាល់ទាត់ បាល់ទះ បាល់បោះ ប៉ុន្តែ មានទីកន្លែងមួយធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ហើយត្រូវកែសម្រួលឡើងវិញនៅក្នុងដំណើររបស់ខ្ញុំ។ នៅពេលដែលខ្ញុំទៅខេត្តព្រៃវែងចុងក្រោយនេះ គ្រូកីឡាបានមកស្នើសុំថា ក្រៅពីតារាងបាល់ទាត់ តារាងបាល់ទះ និងតារាងបោះបោះ សុំកីឡាកាយសម្ព័ន្ធ។ នេះជាការខ្វះការយកចិត្តទុកដាក់របស់យើង មួយ គិតតែពីអារឿងអាទាត់ អាទះ និងអាបោះ ប៉ុន្តែ អាកាយសម្ព័ន្ធ ទាក់ទងនឹងការលោតចម្ងាយ លោត កម្ពស់ ឬចោលដុំដែក ដែលជាប្រភេទកីឡានានា យើងខ្វះការយកចិត្តទុកដាក់អាហ្នឹងទៅវិញ។ អញ្ចឹងទេ បានជាទីតាំងកន្លែងហ្នឹងវាមិនត្រូវការធំពេកទេ។ (រួមជាមួយ)បាល់បោះ យើងក៏ត្រូវរៀបចំនូវទីកន្លែងសម្រាប់ការហ្វឹកហាត់របស់ផ្នែក

*កាយសម្ព័ន្ធផងដែរ ហោចណាស់ក៏ត្រូវមានការលោតចម្ងាយ ការលោតកម្ពស់ ការចោលស្ពឺៗ ដើម្បីធានាថា កីឡារបស់យើងវាទៅជាសំណុំ។*

*អញ្ចឹងទេ ក្នុងវិស័យ អប់រំ យុវជន និងកីឡា របស់យើងផ្នែកកីឡា ត្រូវបន្តការខិតខំ ហើយត្រូវ ហ៊ានវិនិ យោគជាមួយនឹងវិស័យកីឡានេះ។ តាមរយៈការខិតខំទាំងអស់គ្នា ហើយក្នុងហ្នឹងអាច មានសប្បុរសជន ខ្លះជួយទៅលើវិស័យកីឡា ព្រោះថានៅកន្លែងខ្លះ ខ្ញុំទៅមើលក្មេងៗទាត់ គាត់ អត់សូវត្រូវការអីច្រើនប៉ុន្មានទេ។ អាហ្វ្រិកបាត់ដំបូង គាត់អត់ត្រូវ(ការ)ទីធ្លាដូចនៅស្តាតឯណា? ប៉ុន្តែ ត្រូវធ្វើឲ្យវាស្អាតចៀសវាងក្មេងគ្រេចជើង។ គ្រាន់តែតារាង ហើយនិងមានបាល់ឲ្យទាត់ ស្បែកជើងអីឲ្យទាត់ហ្នឹង គាត់ទាត់(ទៅហើយ)។*

## ២.១៧.តួនាទីរបស់នាយកសាលា

តួនាទីរបស់នាយកសាលា : សំដៅដល់អ្នកទទួលខុសត្រូវក្នុងកាលធ្វើអ្វីទាំងអស់ដែលខ្លួនមាន លទ្ធភាពអាចធ្វើបានដើម្បីសម្រួល និងជំរុញឲ្យបុគ្គលិកទាំងអស់បំពេញការងារដោយជោគជ័យ

សាលារៀនដ៏ល្អមួយ ទាមទារនូវនាយកដ៏ល្អមួយ ពីព្រោះនាយកសាលាដ៏ល្អមួយ គឺជាការ ចាំបាច់សម្រាប់ការរៀនប្រកបដោយប្រសិទ្ធភាពរបស់សិស្ស ស្របនឹងពាក្យស្លោកមួយឃ្លាពោល ថា " នាយកសាលាជាបេះដូងរបស់សាលារៀន " ដូចនេះនាយកសាលាត្រូវតែលយ់ដឹងកាន់តែ ខ្លាំងអំពីតួនាទីយ៉ាងសំខាន់ជាសារវន្តរបស់ខ្លួនហើយខិតខំប្រឹងប្រែងធ្វើខ្លួនក្លាយជា បេះដូងរបស់ សាលារៀន ប្រការនេះពិតជាមិនមែនជាការងាយស្រួលទេ ក៏ប៉ុន្តែវាក៏ជាការលំបាកដែលមិនអាច ធ្វើបាននោះដែរ អ្វីដែលត្រូវការដំបូងនោះគឺ ការជឿជាក់ និងឆន្ទៈ។

នាយកសាលាជាអ្នកជួយសាលា និងប្រព័ន្ធអប់រំឲ្យមានដំណើរការ។ រៀបចំចាត់ចែងនិងអនុ វត្តរាល់ការងារទាំងអស់នៅក្នុងអង្គភាព ព្រមទាំងជាអ្នកបណ្តុះបណ្តាលនិងជំរុញឲ្យគ្រូបង្រៀន ចេះរៀន ក្នុងនោះផងដែរគ្រូបង្រៀនមានយុទ្ធវិធីខ្ពស់ ក្នុងការធ្វើឲ្យសិស្សចេះរៀនទទួលបាននូវ លទ្ធផលខ្ពស់ជួយឲ្យសាលារៀនមួយកាន់តែល្អប្រសើរឡើងសម្រាប់សិស្សានុសិស្ស។ក្នុងនោះ នាយកសាលា មានតួនាទីជាអាជ្ញាធរអប់រំ ជាមន្ត្រីរដ្ឋបាល ជាទីប្រឹក្សាគរុកោសល្យ ជាអធិការអ ចិន្ត្រៃយ៍ និងជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍។

១ . ជាអាជ្ញាធរអប់រំ  : នាយកសាលាជាប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំយុវជន កីឡាប្រចាំភូមិសាស្ត្រសិក្សារបស់សាលារៀននីមួយៗជាអ្នកធានាទំនាក់ទំនងការងាររវាងសាលារៀន ជាមួយថ្នាក់លើ ជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទបញ្ញាសិក្សា និងលិខិតបទដ្ឋាននានា។ នាយកសាលាដឹកនាំគ្រប់សកម្មភាព និងធានាឲ្យបាននូវបរសិទ្ធភាពតាមគោលដៅអប់រំ ដែលបានគ្រោងទុកនិងទទួលខុសត្រូវទាំងស្រុងចំពោះសាលារៀន និងថ្នាក់លើនូវរាល់អ្វីដែលកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជាអ្នកសម្របសម្រួល និងបង្រួបបង្រួមគ្រប់កម្លាំងដើម្បីអនុវត្តការងារដោយរលូនជាមួយគ្នា។

២. មន្ត្រីរដ្ឋបាលៈ នាយកសាលាជាអ្នកណែនាំអនុវត្តរដ្ឋបាលសិក្សាទាំងអស់ដែលធានាធ្វើឲ្យសម្រេចគោលនយោបាយអប់រំ ចាត់ចែងសកម្មភាព និងបែងចែកភារកិច្ចឲ្យបុគ្គលិកដោយរិះរកគ្រប់មធ្យោបាយ និងវិធានការចាំបាច់ដើម្បីធ្វើឲ្យសកម្មភាពប្រព្រឹត្តទៅ ប្រកបដោយប្រសិទ្ធិភាពប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

៣. ជាទីប្រឹក្សាគរុកោសល្យ ៖ ក្នុងនាមជានាយក និងជាគ្រូបង្រៀនមានបទពិសោធន៍ ត្រូវយកចិត្តទុកដាក់ផ្តល់ពត៌មាន និងមានសិទ្ធអំណាចណែនាំគរុកោសល្យដល់គ្រូបង្រៀនក្រោមឪវាតអំពីល្បិចនិងវិធីសាស្ត្របង្រៀន និងគន្លឹះល្អៗនៃការបង្រៀនព្រមទាំងស្វ័យសិក្សានិងអភិវឌ្ឍសម្បទានចិត្តគរុកោសល្យដោយខ្លួនឯងឥតឈប់ឈរ។គ្រូបង្រៀនតែងផ្តល់កិត្តិយសនិងគោរព នាយកសាលាណាដែលមានសមត្ថភាពអាចធានាការរៀបចំគរុកោសល្យបានល្អ។ ជាអ្នកផ្តល់យោបល់បច្ចេកទេស និងណែនាំដល់បុគ្គលិក និងគ្រូបង្រៀនឲ្យជឿជាក់លើការគ្រប់គ្រង ព្រមទាំងយល់ដឹងពីចិត្តគំនិត ឥរិយាបថ អាកប្បកិរិយារបស់បុគ្គលិកដែលអាចមានផលប៉ះពាល់ដល់អង្គភាព។ រាល់សំណួរ និងសូមណូមបររបស់បុគ្គលិក នាយកត្រូវតែមានចម្លើយហើយមិនត្រូវធ្វើអាកប្បកិរិយាធុញទ្រាន់ ក្រអើតក្រទម រើសអើងឡើយ ពីព្រោះគ្រប់សូមណូមពរ ចម្ងល់ទាំងអស់បង្ហាញឲ្យឃើញនូវសេចក្តីត្រូវការ ការចង់ចេះ ចង់ដឹងរបស់អ្នកប្រើប្រាស់សេវា ហើយទាំងអស់នេះវាមានសារៈសំខាន់ចំពោះការប្រតិបត្តិការងាររបស់យើងផ្ទាល់ និងធ្វើការកែលម្អ នូវចំណុចខ្លះខាតសំដៅទៅនឹងតម្រូវការរបស់បុគ្គលិក គ្រូបង្រៀន។

៤. ជាអធិការអចិន្ត្រៃយ៍ៈ នាយកសាលារៀបចំផែនការធ្វើអធិការកិច្ចច្បាស់លាស់ រួចផ្សព្វផ្សាយដល់គ្រូបង្រៀននិងមានសិទ្ធិត្រួតពិនិត្យកែលម្អសកម្មភាពអប់រំ ជាពិសេសសកម្មភាព

បង្រៀន និងរៀន។ បន្ទាប់ពីធ្វើអធិការកិច្ចរួច នាយកសាលាតែងតែធ្វើការណែនាំ ដើម្បីជួយកែលម្អ និងវាយតម្លៃ ជំរុញឲ្យការបង្រៀន និងរៀនកាន់តែទទួលបាននូវប្រសិទ្ធិភាពខ្ពស់។

៥. ជាអ្នកចរចារ ៖នាយកសាលាជាអ្នកមានទេពកោសល្យក្នុងការដោះស្រាយវិវាទរបស់បុគ្គលិក និងវិវាទផ្សេងៗដោយសន្តិវិធី ដែលអាចកើតមាននៅក្នុងអង្គភាព។

៦.ជាអ្នកអប់រំ៖ នាយកសាលាជាអ្នកដឹកនាំ គ្រប់គ្រងអប់រំ និងបណ្តុះបណ្តាលបុគ្គលិកគ្រូបង្រៀនដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស ។ មានការបណ្តុះបណ្តាលផ្លូវការ និងមិនផ្លូវការ ការតម្រង់ទិសបណ្តុះបណ្តាលនៅកន្លែងការងារ ការបណ្តុះបណ្តាលផ្នែកបច្ចេកទេស ឬមិនមែនផ្នែកបច្ចេកទេសតាមរយះការប្រជុំឬសិក្ខាសាលានានានៅក្នុងអង្គភាព ឬក្រៅអង្គភាព។ ដូចនេះនាយកសាលាត្រូវតាំងខ្លួនជាប្រធានអ្នករៀន។

៧. ជាអ្នកផ្តល់សេវាកម្ម៖ នាយកសាលាជាអ្នកផ្តួចផ្តើមគំនិតនិងផ្តល់សកម្មភាពជាសេវាកម្មឲ្យបុគ្គលិក កុំឲ្យនៅទំនេរឥតប្រយោជន៍។

៨.ជាអ្នកពិគ្រោះយោបល់ ៖ នាយកសាលាជាអ្នកជួយបុគ្គលិក គ្រូបង្រៀនឲ្យចេះដោះស្រាយបញ្ហាផ្ទាល់ខ្លួន ធ្វើការងារឡើងដោយប្រើវិចារណញាណឆ្ពោះទៅរកឯកភាពគ្នា និងជួយគ្នាទៅវិញទៅមក។

៩.ជាភ្នាក់ងារអភិវឌ្ឍសហគមន៍ ៖ នាយកសាលាមានទំនាក់ទំនងល្អជាមួយគ្រួសារ សហគមន៍ អាជ្ញាធរដែនដី និងស្ថាប័ននានា ដើម្បីជាគុណប្រយោជន៍បុគ្គលិក គ្រូបង្រៀន និងអង្គភាពរបស់ខ្លួន។ ជាភ្នាក់ងារដ៏សំខាន់និងចាំបាច់នៃការអភិវឌ្ឍរបស់សហគមន៍ ជាពិសេសអភិវឌ្ឍចិត្តគំនិត និងស្មារតី ព្រមទាំងមានសិទ្ធិចូលរួមគ្រប់សកម្មភាពរបស់សហគមន៍ពីតួនាទីនិងភារកិច្ចរបស់ " ការអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់ការអប់រំ " ។

## ២.១៨.គ្រូបង្រៀន

គ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់ ក្នុងនាមជាភ្នាក់ងារចម្លង(ផ្ទេរខ្លឹមសារមេរៀន ចំណេះដឹងឲ្យសិស្ស) និងជាភ្នាក់ងារផ្លាស់ប្តូរ(ការពិភាក្សារវាងគ្រូ និងសិស្ស ដើម្បីកំណត់ខ្លឹមសារ និងផ្លាស់ប្តូរសង្គម)។ បន្ថែមពីនេះ គ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមដោយមានជំហរក្លាហានខាងសីលធម៌ និងការរិះគន់ដោយស្ថិតនៅក្នុងតួនាទីជាគ្រូបង្រៀន។ គ្រូបង្រៀនមិនមែន

គ្រាន់តែជាអ្នកទៅសាលា ដើម្បីប្រាប់មេរៀនដែលក្រសួងបានកំណត់នៅក្នុងកម្មវិធីសិក្សា និងមេរៀនដែលតម្រូវឲ្យសិស្សសិក្សារៀនសូត្រនោះទេ។ ប៉ុន្តែក្នុងនាមជាបុគ្គលគ្រូបង្រៀនមួយរូប គឺត្រូវដើរតួនាទីជាច្រើនក្នុងអាជីពរបស់ខ្លួន។ គ្រូបង្រៀនគឺជាឪពុកម្តាយ ជាអ្នកសិក្សាស្រាវជ្រាវ ជាមិត្តភក្តិ ជាមគ្គុទេសក៍ ជាទីប្រឹក្សា ជាអ្នកច្នៃប្រឌិត ជាអ្នកវិភាគ ជាអ្នកកំចាត់បក្សពួកនិយម ជាអ្នកផ្តល់នូវទស្សនវិស័យ ជាអ្នកវាយតម្លៃ ជាសិល្បករ និងជាអ្នកសម្របសម្រួលដ៏ស្ទាត់ជំនាញជាដើម។ល។

មូលហេតុដែលត្រូវចាត់ទុកគ្រូបង្រៀនជាឪពុកម្តាយ ព្រោះថាគ្រូបង្រៀនត្រូវតែរក្សាទឹកចិត្តស្រឡាញ់រាប់អានសិស្សប្រៀបដូចជាកូនរបស់ខ្លួន មានក្តីស្រឡាញ់ មានការអាណិតអាសូរ រក្សាទឹកចិត្តអត់ឱន ស្ថិតស្ថាលក្នុងឋានៈជាឪពុកម្តាយ។ ស្រឡាញ់ និងផ្តល់ចំណេះឲ្យសិស្ស ដោយមិនលម្អៀង ប្រៀបដូចជាឪពុកម្តាយផ្តល់នូវសេចក្តីស្រឡាញ់ដល់កូនៗដូច្នេះដែរ។ បន្ថែមពីនេះគ្រូបង្រៀនក៏ជាមិត្តភក្តិដ៏ល្អជាមួយសិស្សផងដែរនៅក្នុងលំហរនិងកាលខ្លះ។ យ៉ាងណាមិញ គ្រូបង្រៀនក៏ជាអ្នកមគ្គុទេសក៍ ដ៏ចំណានក្នុងការបង្ហាញផ្លូវ ជាអ្នកបំភ្លឺផ្លូវ ដែលមានភាពស្មោះត្រង់មានគុណធម៌ខ្ពស់ចំពោះសិស្សានុសិស្ស។ ក្នុងនោះផងដែរ គ្រូបង្រៀនត្រូវធ្វើជាទីប្រឹក្សា ដែលត្រូវដើរតួនាទីជាអ្នកអប់រំ ជាអ្នកដឹកនាំ ព្រមទាំងផ្តល់ឲ្យសិស្សបានឃើញ បានយល់ពីឧត្តមគតិជឿនលឿន និងបង្ហាញសិស្សពីមាគ៌ាអភិវឌ្ឍនចំណេះដឹង សមត្ថភាព ប្រកបដោយភាពត្រឹមត្រូវ។ ក្នុងនោះផងដែរ គ្រូបង្រៀនក៏ជាអ្នកស្រាវជ្រាវ អ្នកបង្កើតថ្មី និងអ្នកផ្តល់ទស្សនវិស័យ ដល់សិស្សទៅតាមលទ្ធភាព សមត្ថភាពដែលខ្លួនមាន និងព្យាយាមពង្រីកចំណេះដឹងខ្លួនឯងផងដែរ។ កត្តានេះគឺមានន័យថាគ្រូបង្រៀន គឺមិនមែនគ្រាន់តែជាបុគ្គលដែលចាំបាច់ត្រូវតែផ្ទេរចំណេះដឹង និងបង្រៀនទេ។ ប៉ុន្តែគ្រូបង្រៀន គឺជាអ្នកសិក្សាស្រាវជ្រាវមួយរូបដែលត្រូវតែស្វែងរកអ្វីដែលថ្មី យកបង្ហាញនិងពិភាក្សាជាមួយសិស្ស ដើម្បីស្វែងរកគំនិតដែលជួយឲ្យមានភាពជឿនលឿនដល់សង្គមនិងសមត្ថភាពសិស្ស។

បន្ថែមពីនេះគ្រូបង្រៀន ក៏ត្រូវតែជាអ្នកមានជំនាញក្នុងការវិភាគពីអ្វីដែលកើតមាននៅក្នុងសង្គមឲ្យសិស្សបានយល់ បានដឹងក្នុងក្របខណ្ឌវិជ្ជាជីវៈ មានមូលដ្ឋានហេតុនិងផលច្បាស់លាស់ ប៉ុន្តែមិនមែនជាអ្នកបំពុលទស្សនៈ ព្រោះតែនិន្នាការណាមួយទៅលើសិស្សឡើយ។ យ៉ាងណាមិញ គ្រូបង្រៀន ក៏ដូចជាសិល្បករមួយរូបច្នៃសិស្សឲ្យក្លាយជាមនុស្សដែលមានប្រយោជន៍។ ជា

អ្នកវាយតម្លៃសិស្ស ឲ្យសិស្សបានស្គាល់ពីទីតាំងពិតនៃចំណេះដឹង សមត្ថភាពរបស់ពួកគេ។ ជាអ្នកសម្របសម្រួលដល់សិស្ស ក្នុងគ្រប់ស្ថានភាពដែលខ្លួនអាចជួយដល់សិស្សបាន។ ជារួមមកក្នុងកិច្ចការជាគ្រូបង្រៀន មិនមែនគ្រាន់តែទៅបង្រៀនតាមតែមេរៀនដែលគេបានកំណត់នោះទេ។ ប៉ុន្តែត្រូវតែជាអ្នកចេះរំលេចឲ្យសិស្សបានឃើញ ពីសង្គមដែលពួកគេបានរស់នៅផង និងបង្ហាញពីគំនិតជឿនលឿនផង។ ហេតុផលនេះហើយ ទើបអាជីពជាគ្រូបង្រៀនមានតម្លៃ។ ក្នុងគំនិតនេះ មិនមែនលើកឡើងសំដៅទៅលើគ្រូបង្រៀន ដែលមានគំនិតអាក្រក់ ឬមិនមានលក្ខណៈសម្បត្តិសមជាបុគ្គលគម្រូនោះទេ៕

**ក.ទឹកចិត្តគ្រូបង្រៀន**

ទឹកចិត្តគ្រូបង្រៀនគឺជាសន្តានចិត្តដ៏ជ្រាលជ្រៅលើកិច្ចការងារទាំងឡាយដែលត្រូវបង្រៀនសិស្សដោយសេចក្ដីជ្រះថ្លា ដោយមិនប្រកាន់ពីវណ្ណៈសិស្ស។ ទាក់ទងនឹងសន្តានចិត្តនេះ មាតាបិតាឬគ្រូមិនខុសគ្នានោះទេ បើនៅក្នុងសៀវភៅធម៌វិញលោកបានសម្ដែងថា មាតាបិតាជាអាចារ្យទីមួយ ឬជាគ្រូទីមួយជាអ្នកបង្រៀនកូន ឬសិស្សឱ្យចេះនិយាយ ឱ្យចេះដើរ ចេះឈរ ចេះស្លៀកពាក់ គឺមាតា បិតាជាគ្រូដើម។ បន្ទាប់មកគ្រូជាអ្នកផ្ដល់ចំណេះដឹង ចំណេះវិជ្ជាទៅដល់សិស្សគេចាត់ទុកថាជាគ្រូទី២របស់សិស្ស។ ដូចនេះទឹកចិត្តគ្រូ មិនខុសពីមាតាបិតាប៉ុន្មានទេ ដែលមានសន្តានចិត្តទៅលើកូន។ ផ្ដើមពាក្យថាកូនមានន័យថាគ្រូចាត់ទុកកូនសិស្សដូចជាកូនរបស់ខ្លួនដែរ ទឹកចិត្តរបស់គ្រូមានមេត្តា ករុណា មានព្រហ្មវិហារធម៌ចំពោះសិស្ស។ បើខ្វះព្រហ្មវិហារធម៌ ករុណាធម៌ ភារៈកិច្ច ឬកាតព្វកិច្ច របស់គ្រូក៏មិនល្អក្នុងការបង្រៀនដែរ។ មានន័យថាគ្រូត្រូវមានករុណាធម៌ចំពោះសិស្សដោយស្មោះស្ម័គ្រ ដោយមិនគិតពីវណ្ណៈរបស់សិស្សឡើយ ដូច្នេះគ្រូត្រូវស្រឡាញ់សិស្សស្មើៗគ្នា នេះជាទឹកចិត្តរបស់គ្រូ។

**ខ. តួនាទីគ្រូមានចំពោះសិស្ស**

តួនាទីគ្រូមានចំពោះសិស្សមានប្រាំចំណុចគឺ ៖

1. គ្រូត្រូវប្រៀនប្រដៅ អប់រំ ទូន្មាន ណែនាំសិស្ស ដោយទឹកចិត្តជ្រះថ្លា និងពន្យល់សិស្សឱ្យចៀសវាងនូវអំពើផ្សេងៗដែលខុសពីច្បាប់សង្គម ច្បាប់សាលា ច្បាប់ប្រទេស។

2. គ្រូត្រូវផ្ទេរនូវចំណេះដឹង ឬភាពឆ្លាតវៃទាំងឡាយទៅឱ្យសិស្សគ្រប់ៗគ្នា ដោយឥតលាក់លៀម ឬមិនលាក់កំណួច និងលាក់គំនិត។

3. គ្រូត្រូវបង្រៀនសិស្សឱ្យអស់ពីសមត្ថភាព ឬចំណេះដឹងរបស់ខ្លួនដើម្បីឱ្យសិស្សបានទទួលជាធម្មតាសិស្សមិនអាចទទួលបាននូវការផ្ទេរទាំងអស់នោះទេ ដូច្នេះគ្រូត្រូវប្រឹងប្រែងយ៉ាងម៉េចឱ្យសិស្សយល់ និងចាប់យកបាន។

4. គ្រូត្រូវចេះលើកតម្កើង និងសម្តែងពីគុណសម្បត្តិរបស់សិស្សនៅចំពោះមុខលោកគ្រូអ្នកគ្រូចាស់ព្រឹទ្ធាចារ្យនានាជាដើម។

5. គ្រូមានតួនាទីជាអ្នកការពារសិស្សកុំឱ្យកូនសិស្សធ្វើខុសនឹងច្បាប់សង្គម ការពាររឿងខាងក្រៅកុំឱ្យមានបញ្ហាដល់សិស្ស។

នៅពេលដែលគ្រូមានសន្តានចិត្តដ៏ល្អបែបនេះ សិស្សរមែងតបស្នងជូនចំពោះគ្រូវិញ។ កាតព្វកិច្ចរបស់សិស្សមានចំពោះគ្រូ រួមមានប្រាំចំណុចដែរ គឺ ៖

1. ជាសិស្សត្រូវធ្វើជាសិស្សល្អ ជាសិស្សគំរូ មានន័យថាគោរពច្បាប់រដ្ឋ ច្បាប់ចរាចរណ៍ ពេលក្នុងសាលាត្រូវគោរពច្បាប់សាលា វិន័យសាលា ពេលក្នុងថ្នាក់ត្រូវគោរពលោកគ្រូអ្នកគ្រូ ចាស់ព្រឹទ្ធាចារ្យ។ ឧទាហរណ៍ ពេលដែលលោកគ្រូអ្នកគ្រូ ឬអ្នកដទៃចូលមក ជាសិស្សត្រូវក្រោកឈរនេះជាការសម្តែងនូវការគោរពរបស់សិស្ស។ បើតាមទំនៀមទម្លាប់ខ្មែរវិញ ពេលក្រោកឈរឡើងតែងតែមានការអមដោយការលើកដៃសំពះទៀតផង។

2. ជួយធ្វើការងារឱ្យគ្រូ ប្រសិនពីដើមវិញសិស្សភាគច្រើនទៅរៀនគឺទៅនៅជាមួយគ្រូ ប៉ុន្តែបច្ចុប្បន្ននេះសិស្សទៅរៀនគឺ មិនមែននៅជាមួយគ្រូទេ។ ពីដើមពេលទៅរៀននៅវត្តសិស្សត្រូវរៀន និងនៅជាមួយលោក ដូចនេះលោកគឺជាគ្រូ សិស្សត្រូវបម្រើ លោកដោយការដាំទឹកក្តៅ ទឹកត្រជាក់ ធ្វើកិច្ចការគ្រប់បែបយ៉ាង មានន័យថាមករស់នៅជាមួយលោកដូចជាគ្រូដែរ។ ពេលចប់ពីការសិក្សា ឬវិស្សមកាលទើបសិស្សអាចត្រឡប់ទៅលំនៅដ្ឋានវិញ។

3. ត្រូវយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ពេលគ្រូបង្រៀនសិស្សត្រូវស្តាប់ មិនត្រូវជជែកគ្នា ឬឡូឡាក្នុងថ្នាក់ទេ មិនត្រូវរំខានពេលគ្រូកំពុងពន្យល់នោះទេ។ គ្រូឱ្យកត់អ្វី សិស្សត្រូវយកចិត្តទុកដាក់ក្នុងការកត់ និងស្តាប់ ប្រសិនជារៀនមិនយល់ត្រូវចេះសួរ។អង្គអ្នករៀនមានបួនគឺសុចិបុលិ។

4. សិស្សត្រូវបម្រើគ្រូជាលក្ខណៈតូចៗ មានដូចជាគក់ច្របាច់ជាដើម។

5. រៀនចំណេះវិជ្ជាគ្រប់បែបយ៉ាងដោយយកចិត្តទុកដាក់ពេលគ្រូបង្រៀន សិស្សត្រូវយកចិត្តទុកដាក់ស្តាប់។ សិស្សត្រូវចេះគោរពច្បាប់រដ្ឋ ច្បាប់សាលា ច្បាប់សង្គម ច្បាប់គ្រួសារ ជាពិសេសត្រូវចេះឱ្យតម្លៃគ្រូ និងយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ដូចសុភាសិតខ្មែរបានពោលថា ចេះពីរៀន មានពីរក។

ដំបូន្មានរបស់អ្នកប្រឹក្សា

ទាក់ទងនឹងដំបូន្មាននេះ ព្រះតេជគុណមានសង្ឃដីកាថា ទាំងលោកគ្រូអ្នកគ្រូត្រូវជាគ្រូដ៏ល្អរបស់សិស្ស ធ្វើយ៉ាងណាត្រូវបំពេញកាតព្វកិច្ចតួនាទីជាគ្រូ ទាំងពាក្យសំដី ទាំងកាយវិការ ត្រូវប្រើពាក្យសំដីល្អ និយាយអ្វីត្រូវតែគិតគូរជាមុនសិន។ ទាំងការនិយាយទាំងការដើរ មានន័យថា គ្រប់ឥរិយាបថ គ្រូត្រូវជាគំរូល្អ ត្រូវមានសីលធម៌ល្អ ត្រូវមានសុវជីវធម៌ ត្រូវមានគុណធម៌ ដើម្បីជាគំរូដ៏ល្អដល់សិស្ស ដើម្បីឱ្យសិស្សទទួលយកគំរូល្អពីគ្រូ។ បើសិស្សត្រូវយកចិត្តទុកដាក់រៀនសូត្រ ព្រោះចំណេះដឹងគឺជាផ្លូវមួយដ៏ប្រសើរសម្រាប់ថ្ងៃអនាគត។ បើទៅសាលារៀន មិនមែនទៅរៀនដើម្បីបានសញ្ញាបត្រ ចប់ឌីប្លូម ចប់បាក់ឌុប ឬបានបរិញ្ញាបត្រ បានអនុបណ្ឌិត និងបណ្ឌិតនោះទេ ទៅរៀនដើម្បីធ្វើការអប់រំខ្លួនឱ្យទៅជាមនុស្សល្អ នេះជាចំណុចសំខាន់សម្រាប់មនុស្សម្នាក់ៗ មិនមែនគ្រាន់តែទៅរៀនយកចំណេះដឹងដាក់ខ្លួនដើម្បីធ្វើការងារ ដើម្បីស៊ីឈ្នួលគេ ដើម្បីទៅបម្រើគេ ដើម្បីធ្វើជាអ្នកដឹកនាំគេនោះទេ វាមិនទាន់ថាល្អនោះទេ។ ដូចពាក្យខ្មែរយើងបានចែងថា បុរសសង្ហាដោយវិជ្ជា នារីសោភាដោយចរិយា បុរសមានវិជ្ជាខ្វះចរិយាប្រៀប ដូចសុរិយាអត់មានរស្មី មានវិជ្ជាប៉ុន្តែខ្វះចរិយា ខ្វះមារយាទ ខ្វះគុណធម៌ ខ្វះសីលធម៌ ដូចជាព្រះអាទិត្យរះមកប៉ុន្តែអត់មានពន្លឺ។

**គ. លក្ខណៈសម្បត្តិរបស់គ្រូបង្រៀន**

**១. លក្ខណៈរូបសម្បត្តិ**

មានកាយសម្បទាមាំមួន

មានរូបរាងកាយសមរម្យ (សំឡេង អវយវៈគ្រប់គ្រាន់ គឺវិញ្ញាណល្អទាំង៥)

មានសុខភាពល្អរឹងមាំ (មុនចូលបម្រើការងារត្រូវមានការកាយសម្បទាឬវិញ្ញាបនបត្របញ្ជាក់) តែជនពិការក៏អាចចូលបម្រើការងារបានដែរ (យោងតាមសមធម៌សង្គម និងយេនឌ័រ)

កម្ពស់សមស្នួន (មិនទាន់ឃើញមានការកំណត់ច្បាស់លាស់អំពីកម្ពស់ទេនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា)។

**២. ចរិយាសម្បត្តិ**

ត្រូវមានឥរិយាបទ ដេក ដើរ ឈរ អង្គុយ ទន់ភ្លន់ ម៉ឺងម៉ាត់ ប្រកបទៅដោយសីលធម៌វិជ្ជាជីវៈខ្ពស់សមជាអ្នកអប់រំ

ត្រូវប្រើប្រាស់ពាក្យពេចន៍ ពាក្យសម្ដីយ៉ាងពីរោះពិសា ផ្អែមល្ហែម សម្លៀកបំពាក់សមរម្យជាគ្រូបង្រៀន (អាវក្នុងសម្ពត់ ឬខោ)

មានចិត្តស្មោះត្រង់ ប្រកាន់យកនូវយុត្តិធម៌ប្រកបដោយព្រហ្មវិហារធម៌ សច្ចធម៌។

មានមនសិការវិជ្ជាជីវៈ ស្របតាមអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ពោលគឺត្រូវៈ

១.គ្រូបង្រៀនត្រូវគោរពជីវិត រាងកាយ ចិត្ត និសេចក្តីថ្លៃថ្នូររបស់មនុស្ស ក្នុងពេលប្រកបរបរវិជ្ជាជីវៈ។ គ្រូបង្រៀនប្រកាន់ខ្ជាប់សីលធម៌ក្នុងការប្រកបវិជ្ជាជីវៈ។

២.គ្រូបង្រៀន ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈក្នុងលក្ខខណ្ឌ ដែលបានកំនត់ដោយច្បាប់ និងបទបញ្ញត្តិនានា ដើម្បីផលប្រយោជន៍របស់អ្នកសិក្សា។

ត្រូវប្រកាន់ខ្ជាប់នូវឥស្សរៈភាពវិជ្ជាជីវៈឯករាជ្យសេរីភាព និងឧត្តមភាពក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនជាអាទិ៍ៈ

១.គ្រូបង្រៀនត្រូវស្តាប់ ពិនិត្យ ឲ្យដំបូន្មានឬធ្វើជាអាណាព្យាបាល(ឪពុកម្តាយទី២) អ្នកសិក្សាទូទៅដោយអនាគត និងមិនប្រកាន់វណ្ណៈ ប្រភព ភេទ ភាសា ពណ៌ ពូជសាសន៍ អម្បូរ ជំនឿសាសនា ដើមកំណើត ពិការភាព សម្បុរ និន្នាការនយោបាយ ឬឋានៈសង្គម ធនធាន ស្ថានភាព ឯទៀតនៅក្នុងការអប់រំ និងសេវាអប់រំ។

២.គ្រូបង្រៀនប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀនមានករណីយកិច្ចរៀបចំកិច្ចតែងការបង្រៀន និងកំនត់ការពន្យល់សំដៅធានាគុណភាពនិងប្រសិទ្ធភាពនៃការបង្រៀន។

៣.គ្រូបង្រៀនត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំង បង្កើនចំណេះដឹងរបស់ខ្លួននិងចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ។ គ្រូបង្រៀនត្រូវធ្វើស្វ័យវាយតម្លៃនិងវាយតម្លៃទៅលើការប្រតិបត្តិវិជ្ជាជីវៈបង្រៀន។

៤.គ្រូវបង្រៀនមានករណីយកិច្ច គាំទ្រសកម្មភាពអប់រំ និងសេវាអប់រំរបស់អាជ្ញាធរអប់រំគ្រប់លំដាប់ថ្នាក់ទាំងអស់។

៥.គ្រូបង្រៀនត្រូវនិយាយស្ដីដោយប្រុងប្រយ័ត្ន និងគិតទៅដល់ប្រតិឃាត នៃពាក្យសម្ដី (និយាយវាយប្រហារ) របស់ខ្លួនចំពោះអ្នកសិក្សា និងសាធារណជនទូទៅក្នុងការផ្ដល់ព័ត៌មានអំពីការអប់រំ ទាំងសាធារណៈទាំងឯកជនទាំងគ្រប់មធ្យោបាយផ្សព្វផ្សាយ។

៦.គ្រូបង្រៀនមិនត្រូវធ្វើប្រជាភិថុតិ ចំពោះអ្នកសិក្សាឡើយ។

៧.គ្រូបង្រៀន មិនត្រូវផ្សព្វផ្សាយអំពីការវិនិច្ឆ័យរដ្ឋបាលបុគ្គលនៅក្នុងមជ្ឈដ្ឋានអប់រំ ក៏ដូចជាក្នុងមជ្ឈដ្ឋានសាធារណៈឡើយ

៨.គ្រូបង្រៀនមិនត្រូវសមគំនិតតាម ផ្លូវកាយឬតាមផ្លូវមធ្យោបាយ ដែលធ្វើឲ្យខូចប្រយោជន៍ អ្នកសិក្សា ក្នុងសេវាអប់រំឡើយ។

៩.គ្រូបង្រៀនមិនត្រូវដាក់ទណ្ឌកម្មខាងផ្លូវកាយ និងផ្លូវចិត្តដែលនាំឲ្យមាន ផលប៉ះពាល់ដល់អ្នកសិក្សាទេ។

១០.គ្រូបង្រៀនមិនត្រូវរៃអង្គាសប្រាក់ ឬប្រមែប្រមូលនូវ ប្រាក់ក្រៅផ្លូវការ ឬធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ។ គ្រូបង្រៀនត្រូវចៀសវាងការប្រកបមុខរបរផ្សេងក្នុងបរិវេណគ្រឹះស្ថានសិក្សា។

១១.គ្រូបង្រៀនត្រូវចៀសវាងការប្រព្រឹត្តអំពើទាំងឡាយណាដែលធ្វើឲ្យអាប់ឱនដល់កិត្តិយស និងវិជ្ជាជីវៈរបស់ខ្លួន។

១២.គ្រូបង្រៀន មិនត្រូវផ្ដល់ការសម្រួលគ្រប់បែបយ៉ាង ដែលនាំឲ្យខ្លួនធ្វើខុសច្បាប់ និងបទបញ្ជាឡើយ។

**៣. ចំណេះដឹង**

គ្រូបង្រៀនត្រូវមានចំណេះដឹងទូលំទូលាយ

ត្រូវមានកម្រិតវប្បធម៌ខ្ពស់ (សិក្សាស្រាវជ្រាវបន្ថែមជាប្រចាំថ្ងៃ)

ត្រូវមានចំណេះដឹងផ្នែចិត្តគរុកោសល្យ(ដោយត្រូវស្វែងយល់អំពីចិត្តសាស្ត្ររបស់សិស្សនីមួយៗ)

ត្រូវចេះប្រើប្រាស់វិធីសាស្ត្រទំនើបទាន់សម័យនិងល្បិចក្នុងការបង្រៀនយ៉ាងប៉ិនប្រសប់

ត្រូវមានបទពិសោធន៍ក្នុងការបង្រៀនយ៉ាងស្ទាត់ជំនាញគោរពតាមគោលដៅអប់រំជាតិពោលគឺចេះអប់រំសិស្សឲ្យក្លាយទៅជាមនុស្សពេញលេញ ក្លាយជាពលរដ្ឋល្អ ជាធនធានមនុស្សដ៏មានស

ក្លានុពលសម្រាប់កសាងប្រទេសនិងអភិវឌ្ឍសង្គមឲ្យរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សដូចបណ្ដាប្រទេសក្នុងតំបន់និងសាកលលោក។

**៩.ចំណេះធ្វើ**

គ្រូបង្រៀនត្រូវខិតខំធ្វើឲ្យបានសម្រេចតាមគោលដៅអប់រំជាតិ

ត្រូវក្ដាប់ឲ្យបាននូវតម្រូវការជាក់ស្ដែងរបស់សង្គម តាមទីផ្សារបលកម្មហៅថាសាលាផ្សារភ្ជាប់សង្គមឬទ្រឹស្ដីត្រូវផ្សារភ្ជាប់និងការងអនុវត្តជាក់ស្ដែងពោលគឺការប្រតិបត្តិ។

ត្រូវចេះបណ្ដុះបណ្ដាលធនធានមនុស្សត្រូវផ្សារភ្ជាប់នឹងទីផ្សារពលកម្មដែលជាហេតុនាំឲ្យសិស្សដែលចេញពីសាលាងាយរកការងារធ្វើ។

ត្រូវមានចំណេះដឹងរស់នៅក្នុងសង្គមធ្វើឲ្យសង្គមធ្វើឲ្យសង្គមមួយមានសីលធម៌ល្អរស់នៅប្រកបដោយសុខដុមរមនា។

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ គម្រោងវិភាគ

ការស្រាវជ្រាវលើប្រធានបទ ស្ថានភាពការបង្រៀន និងរៀនអប់រំកាយ និងកីឡានៅមធ្យមសិក្សា ក្នុងគោលបំណងរកឲ្យឃើញនូវមូលហេតុដែលធ្វើឲ្យមុខវិជ្ជានេះមិនមានដំណើការល្អនៅក្នុងសាលារៀន។ អ្នកស្រាវជ្រាវបានសម្រេចជ្រើសរើសការសិក្សាស្រាវជ្រាវបែបគុណវិស័យ ( Qualitative) ដែលតម្រូវឲ្យមានយុទ្ធសាស្ត្រនៃការរៀបចំគម្រោងសិក្សា ការបង្កើតទំហំ និងការជ្រើសរើសចំនួនសំណាគម្រូ។ ដើម្បីបានជាទុនក្នុងការសិក្សាស្រាវជ្រាវ យើងបានស្រាវជ្រាវឯកសាផ្សេងៗនៅតាមសាលា តាមបណ្ណាល័យជាច្រើន និងជ្រើសរើសឯកសាដែលទាក់ទងទៅនឹងប្រធានបទ ដើម្បីយកគោលគំនិតក្នុងការស្រាវជ្រាវ។ មិនតែប៉ុណ្ណោះ គឺបានសិក្សាស្រាវជ្រាវដោយមានការប្រមូលព័ត៌មាន របាយការណ៍សន្និបាទអប់រំ របាយការណ៍នានាដែលពាក់ព័ន្ធ នឹងកម្មវិធីដែលសិក្សាផ្នែកអប់រំកាយ និងកីឡានៅតាមសាលារៀន ជាពិសេសគឺនាយដ្ឋានអប់រំកាយ និងកីឡាសិស្សនិស្សិត។ក្រៅពីការស្រាវជ្រាវតាមប្រភពផ្សេងៗយើងបានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតក្នុងការស្រាវជ្រាវនូវទស្សនៈ និងទ្រឹស្តីរបស់គរុវិទូមួយចំនួនដែលទាក់ទងជាមួយនឹងប្រធានបទផងដែរ។ ចំណុចសំខាន់គឺការចុះប្រមូលទិន្នន័យតាមរយៈកម្រងសំណួរសម្ភាសន៍ពីគ្រប់មុខសញ្ញាដែលពាក់ព័ន្ធទៅតាមការដែលបានគ្រោងទុក។

## ៣.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវវត្ថុបំណងស្រាវជ្រាវ អ្នកស្រាវជ្រាវបានជ្រើសរើសអនុវិទ្យាល័យចំនួន ៥ និងវិទ្យាល័យចំនួន៣ គ្រូបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡា ២១នាក់ សិស្សានុសិស្ស២០ក្រុម និងគណៈគ្រប់គ្រងសាលារៀន ដែលស្ថិតនៅក្នុងស្រុកកៀនស្វាយសម្រាប់ការសិក្សាស្រាវជ្រាវ។ បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតចុះស្រាវជ្រាវពីវិទ្យាស្ថានជាតិអប់រំ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាលរួចមក វីធីសាស្ត្រដែលបានយកមកប្រើប្រាស់ដើម្បីសរសេរបញ្ចប់របាយការណ៍លើប្រធានបទស្តីពី " ស្ថានភាពការរៀន និងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅមធ្យមសិក្សា " គឺអ្នកស្រាវជ្រាវបានចុះទៅតាមអនុវិទ្យាល័យ និងវិទ្យាល័យគោលដៅទាំង ០៨ ដើម្បីស្នើរសុំគ្រូបង្រៀន និងសិស្សានិសិស្ស រួមទាំងទៅសម្ភាសន៍នាយកសាលាគោលដៅទាំងអស់។ ចំណែកលទ្ធផលទទួលបានគឺឆ្លុះបញ្ចាំងអំពីទស្សនៈ និងលទ្ធផលសិក្សារបស់អ្នកចូលរួមក្នុង

ស្រុកកៀនស្វាយតែប៉ុណ្ណោះដោយមិនទាក់ទងនិងឆ្លុះបញ្ចាំងនៅទូទាំងខេត្តឬទូទាំងប្រទេសឡើយ។

### ៣.២.១ វិធីសាស្ត្រប្រមូលទិន្នន័យ

វិធីសាស្ត្រប្រមូលទិន្នន័យ គឺប្រើប្រាស់តាមបែបគុណវិស័យ។ ដើម្បីឲ្យការស្រាវជ្រាវនេះទទួលបានជោគជ័យ គឺចាំបាច់ទាមទានូវប្រភពព័ត៌មាននិងប្រភពទិន្នន័យគ្រប់គ្រាន់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការបកស្រាយ តាមរយៈការប្រមូលទិន្នន័យចម្បង និងទិន្នន័យមានស្រាប់។

**ក.ទិន្នន័យចម្បង៖** ទិន្នន័យចម្បងនឹងត្រូវប្រមូលតាមរយៈកម្រងសំណួរសម្រាប់សម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធក្នុងគោលបំណងរកឲ្យឃើញនូវបញ្ហាប្រឈមនានាដែលទាក់ទងនឹងមុខវិជ្ជានេះ និងរកឲ្យឃើញនូវមូលហេតុដែលមុខវិជ្ជាអប់រំកាយ និងកីឡាមិនមានដំណើរការល្អនៅក្នុងសាលារៀនដែលក្នុងនោះរួមមាន៖

**កម្រងសំណួរសម្រាប់សម្ភាសន៍** គឺសម្ភាសន៍គ្រូបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡាបន្ថែមពីលើកម្រងសំណួរ នាយកសាលាគោលដៅទាំងអស់ ដើម្បីស្វែងរកហេតុផលនានាទាក់ទងទៅនឹងប្រធានបទនៃការស្រាវជ្រាវ ដែលជាទិន្នន័យបែបគុណវិស័យ។

**ខ.ទិន្នន័យមានស្រាប់** ទិន្នន័យបន្ទាប់បន្សំប្រមូលបានពីឯកសារបោះពុម្ពនានា ក្នុងគោលបំណងសិក្សាស្វែងយល់ពីទ្រឹស្តីនានាដើម្បីធ្វើជាអំណះអំណាង និងគាំទ្រដល់ការសរសេររំលឹកទ្រឹស្តី និងការបកស្រាយលទ្ធផលរួមមាន៖ រដ្ឋធម្មនុញ្ញអន្តរជាតិ ស្តីពីអប់រំកាយ សកម្មភាពរាងកាយ និងកីឡា (UNESCO 2015 បុព្វកថា ១៧ វិច្ឆិកា ២០១៥) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រាទី៦៥នៃច្បាប់អប់រំ កម្មវិធីលម្អិតអប់រំកាយ និងកីឡា និងឯកសារដែលពាក់ព័ន្ធនានា។

### ៣.២.២ ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ

យើងបានរៀបចំកម្រងសំណួរសម្រាប់សម្ភាសន៍ លើប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកកៀនស្វាយ នាយកវិទ្យាល័យ និងអនុវិទ្យាល័យទាំងអស់ក្នុងស្រុកកៀនស្វាយ លោកគ្រូ អ្នកគ្រូអប់រំកាយ និងកីឡាដើម្បីសម្រេចនូវគោលបំណងស្រាវជ្រាវខាងលើជាមួយសំណួរសម្ភាសន៍ បែបគុណវិស័យ។

### ៣.២.៣ វិធីសាស្ត្រជ្រើសរើសភាគសំណាក

ការជ្រើសរើសភាគសំណាក គឺជាផ្នែកសំខាន់នឹងត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នដើម្បីចង់បានព័ត៌មានល្អ។ ហេតុនេះហើយ អ្នកស្រាវជ្រាវជ្រើសរើសភាគសំណាកពីសាលាជាច្រើនដើម្បីបានព័ត៌មានពិតមកវិភាគឲ្យបានត្រឹមត្រូវ។ ចំពោះពាក្យសំណាកគឺជ្រើសរើសគ្រូបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅតាមអនុវិទ្យាល័យចំនួន ០៥និងវិទ្យាល័យចំនួន ០៣ដ គឺរួមមាន វិទ្យាល័យជ័យវរ្ម័នទី៧ វិទ្យាល័យហ៊ុនសែនសិរីដីដុះ វិទ្យាល័យសាន់នីវ៉ូសំរោងធំ អនុវិទ្យាល័យគគីរ អនុវិទ្យាល័យរទាំង អនុវិទ្យាល័យបន្ទាយដែក និងអនុវិទ្យាល័យឬស្សីស្រុក។

### ៣.២.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់នូវវិធីសាស្ត្របែបគុណវិស័យ ដើម្បីពិព័ណ៌នាអំពីស្ថានភាពទូទៅនៃការអនុវត្តមុខវិជ្ជាអប់រំកាយ និងកីឡាក្នុងស្រុកកៀនស្វាយ និងកំណត់ពីការយល់ឃើញរបស់ នាយក នាយិកាសាលា លោកគ្រូ អ្នកគ្រូ និងប្អូនៗសិស្សានុសិស្សផ្តោតលើប្រធានបទស្រាវជ្រាវខាងលើ។

ចំពោះទិន្នន័យបែបគុណវិស័យ ដែលទទួលបានតាមរយៈកម្រងសំណួរបើក ត្រូវបានអាន និងវិភាគដោយធ្វើចំណាត់ថ្នាក់ទៅតាមប្រធានបទនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ព្រមទាំងបញ្ហាប្រឈមនានាទាក់ទងទៅនឹងការអនុវត្តកម្មវិធីអប់រំកាយ និងកីឡានៅមធ្យមសិក្សា។លើសពីនេះទៀតព័ត៌មានទាំងនេះត្រូវបានប្រើប្រាស់ដើម្បីពិភាក្សាលើលទ្ធផលដែលបានពីទិន្នន័យបែបគុណវិស័យ។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

## ១.សេចក្តីផ្តើម

ការសិក្សាស្រាវជ្រាវលើប្រធានបទ"ស្ថានភាពក្នុងការរៀន និងបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានូវមធ្យមសិក្សា " មានគោលបំណងរកឲ្យឃើញពីស្ថានភាពនឹងកត្តាដែលធ្វើឲ្យមុខវិជ្ជាអប់រំកាយ និងកីឡាមិនមានដំណើរការល្អនៅក្នុងសាលារៀន ក្នុងស្រុកកៀនស្វាយ ដោយឆ្លើយតបនឹងសំនួរដូចខាងក្រោម ៖

តើការអនុវត្តមុខវិជ្ជាអប់រំកាយ និងកីឡាមានស្ថានភាពដូចម្តេច?

តើកត្តាអ្វីខ្លះដែលធ្វើឲ្យ មុខវិជ្ជាអប់រំកាយ និងកីឡាមិនមានដំណើរការល្អនៅក្នុងសាលារៀន?

នៅក្នុងដំណើរការក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានអនុវត្តទៅតាមជំនាក់កាលដោយបានសម្ភាសន៍ប្រធានការិយាល័យ លោកនាយកសាលា ៦នាក់ និងលោកស្រីនាយិការ១នាក់ លោកគ្រូអ្នក អ្នកគ្រូ២១នាក់ សិស្សានុសិស្ស២០ក្រុម ដើម្បីបានទិន្នន័យដែលទាក់ទងនឹងប្រធានបទ។

### ព័ត៌មានទូទៅចំពោះសំណាកដែលចូលរួម




បទពិសោធន៍ការងាររបស់ប្រធានការិយាល័យ
ជាគ្រូបង្រៀន
ប្រធានការិយាល័យ
អនុប្រធានការិយាល័យ
១០
២
១៦


កម្រិតវប្បធម៌ និងឯកទេសនាយកសាលា
១០
៨
៦
៤
២
០
១
៧
៨
៦
២
៥
៣
នាយកសាលា
ស្រី
ប្រុស
សរុប
អនុបណ្ឌិត
បរិញ្ញាបត្រ
ឯកទេសវិទ្យាសាស្រ្តពិត
ឯកទេសវិទ្យាសាស្រ្តសង្គម


គ្រូបង្រៀន
១៨
១៦
១៤
១២
១០
៨
៦
៤
២
០
១៧
១៣
៥
៤
៣
គ្រូបង្រៀន
ស្រី
ប្រុស
ចង់ធ្វើគ្រូបង្រៀន
គ្មានជម្រើស
តាមឪពុកម្តាយ


ការសិក្សាបន្តរបស់គ្រូអប់រំកាយ និងកីឡា
២០
១៥
១០
៥
០
១៧
៤
៥
៥
២
គ្រូបង្រៀន
ស្រី
ប្រុស
បានបំប៉នបន្ថែមលើមុខវិជ្ជាឯកទេស

ឆ្លងតាមការសម្ភាសន៍យើងបានរកឃើញ និងបែងចែកទៅតាមផ្នែកដូចខាងក្រោមៈ

## I.**កម្មវិធីសិក្សា**

តាមលទ្ធផលនៃការសម្ភាសន៍ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកកៀនស្វាយ លោកមានប្រសាសន៍ថា៖ យើងមានរបាយពិន្ទុ និងរបបម៉ោងសិក្សា ប៉ុន្តែគាត់ពុំបានទទួលកម្មវិធីលម្អិត ឬទទួលបានសៀវភៅសិក្សាគោលអប់រំកាយ និងកីឡានោះទេ អ្វីដែលគាត់ទទួលបានគឺមានតែទស្សនាវត្តីកីឡាតែប៉ុន្នោះ រីឯកម្មវិធីប្រកួតវិញថ្នាក់ខេត្តមានកម្មវិធីប្រកួតជារៀងរាល់ឆ្នាំមិនដែលខានទេ ហើយយើងក៏បានចូលរួមជារាងរាល់ឆ្នាំដែរ។

ក្នុងនោះផងដែរ លោកនាយកសាលា លោកស្រីនាយិកា វិទ្យាល័យ និង អនុវិទ្យាល័យទាំងអស់បានបញ្ជាក់ថាៈចំពោះពួកគាត់កមិនបានដឹងច្បាស់ពីសៀវភៅសិក្សាគោលអប់រំកាយ និងកីឡានោះដែរ ពោលគឺ ពួកគាត់ទទួលបានកម្មវិធីហ្វឹកហាត់ និងរបាយការហ្វឹកហាត់កីឡាប្រចាំឆ្នាំពីគ្រូអប់រំកាយនិងកីឡា ចំណែកសៀវភៅសិក្សាគោលសម្រាប់សិស្សានុសិស្សក៏មិនមានដែរ វាអាស្រ័យលើការរៀបចំរបស់គ្រូកីឡាម្នាក់ៗ និងប្រធានក្រុមមុខវិជ្ជាតែប៉ុន្នោះ ឯកម្មវិធីប្រកួតពេលខ្លះក៏រៀបចំ ពេលខ្លះក៏គ្មានគឺអាស្រ័យលើថវិកាមានកំនត់។

លោកនាយកសាលាមួយ លោកបានបន្ថែមលើចំណុចនេះថាៈ រឿងកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយ និងកីឡាមិនមានទេ យើងធ្វើវារៀងរាល់ឆ្នាំជាមួយគ្រូកីឡា ឆ្នាំខ្លះខ្ញុំបានជួយធ្វើគាត់ទៀតផង។ នាយកវិទ្យាល័យរូបទៀតបានបន្ថែមថាៈ គាត់ធ្វើការជាង២០ឆ្នាំហើយមិនដែលបានទទួលសៀវភៅសិក្សាគោលអប់រំកាយ និងកីឡានោះទេ គាត់កចង់បានសម្រាប់ពិនិត្យតាមដានលើគ្រូកីឡាដែរ ប៉ុន្តែឥឡូវ មិនដឹងពិនិត្យយ៉ាងដូចម្តេចទេ ព្រោះគ្មានកម្មវិធីលម្អិត និងសៀវភៅសិក្សាគោលច្បាស់លាស់ ។

ជាពិសេសលោកគ្រូ អ្នកគ្រូអប់រំកាយ និងកីឡា បានបញ្ជាក់ថា ៈពួកគាត់សព្វថ្ងៃ មិនមានសៀវភៅសិក្សាគោលច្បាស់លាស់នោះទេ ពោលគឺពួកគាត់ធ្វើអ្វីទៅតាមអ្វីដែលគាត់បានដឹង និងចេះតែប៉ុន្នោះ។ ការប្រើប្រាស់ សៀវភៅសព្វថ្ងៃ គឺពីសៀវភៅផ្សេងៗ មិនដូចគ្នានោះទេ វាអាស្រ័យទៅលើគ្រូម្នាក់ៗ ថាតើពួកគាត់ចង់បង្ហាត់អ្វី ។មានន័យថា ពួកគាត់មានជំនាញអ្វី ហើយ

ចូលចិត្តអ្វីគាត់បង្ហាត់នឹង មិនបានផ្តោតលើកម្មវិធីសិក្សានោះទេ ។ ចំណែកការប្រកួតវិញ ជួនមានការប្រកួត ជួនកាលគ្មានការប្រកួតទេ គឺថ្នាក់ស្រុកចាត់តាំងតែម្តង មិនទៀងទាត់ទេ។

## II.បរិក្ខានិងបរិស្ថានសាលារៀន

### ក.បរិក្ខាកីឡា








ប៉ុន្តែអ្វីដែលយើងទទួលបាន ពីការសម្ភាសន៍គឺៈ នាយកសាលាមួយរូបបានមានប្រសាសន៍ថា ៈគាត់មិនមានថវិការគ្រប់គ្រាន់ក្នុងការទិញ សម្ភារកីឡាគ្រប់ប្រភេទសម្រាប់កីឡានោះទេ ។

សម្រាប់សម្ភារកីឡាមួយចំនួនគឺបានផ្តល់ដោយក្រសួង ឬបានទទួលពីមន្ទីរជារៀងរាល់ឆ្នាំយើងមិនបាច់ស្នើរសុំទេ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ សម្ភារដែលបានទទួលមិនទៀងទាត់ ហើយមិនស្របតាមតម្រូវការ។ នាយកសាលាដ៏ទៃទៀត ក៏មានប្រសាសន៍ស្រដៀងគ្នាដែរទាក់ទងនិងបញ្ហានេះ ពោលគឺមានការខ្វះខាតលើសម្ភារកីឡាស្ទើរតែគ្រប់មុខ។ លោកនាយកសាលាវិទ្យាល័យមួយរូបទៀត បានបញ្ជាក់ថាៈ សម្ភារកីឡាមានការខ្វះខាតមួយចំនួនដែរពីមុន តែបានការជួយឧបត្ថមពីអង្គការដៃគូរមួយចំនួនធំ ឥឡូវយើងមិនសូវខ្វះខាតខ្លាំងទេ។

ចំពោះលោកគ្រូ អ្នកគ្រូអប់រំកាយ និងកីឡាវិញមានប្រសាសន៍ថាៈ សម្ភារសម្រាប់ហ្វឹកហាត់ក្នុងម៉ោងកីឡាមានការខ្វះខាតខ្លាំង ទាំងសម្ភារសម្រាប់ទ្រទ្រង់ក្នុងការហ្វឹកហាត់ និងសម្ភារសម្រាប់ហាត់ផ្ទាល់។ ពួកគាត់បន្ថែមថា ឆ្នាំខ្លះពួកគាត់បានស្នើរសុំគណៈគ្រប់គ្រងសាលាជារៀងរាល់ឆ្នាំ ប៉ុន្តែអ្វីដែលទទួលបាន មិនដូចអ្វីដែលគេស្នើរសុំ ហើយមានការយឺតយ៉ាវទៀតផង ។ ពេលខ្លះពួកគាត់ទិញដោយខ្លួនឯង នឹងពេលខ្លះទៀតសិស្សយកមកដោយខ្លួនឯង ប៉ុន្តែមិនគ្រប់ទេ ពួកគេមានតែរបស់ដែលពួកគាត់ចូលចិត្តប៉ុន្នោះ ភាគច្រើនមានតែបាល់ ឯសម្ភារដ៏ទៃមិនមាននោះទេ។ រីឯលោកគ្រូកីឡានៅសាលាមួយ បានលើកឡើងថាៈ គាត់មានការពិបាកច្រើនក្នុងការស្នើរសុំទិញឬកសាងអ្វីផ្សេងៗដែលបម្រើឲ្យសកម្មភាពកីឡា ហើយគាត់ក៏មិនទាមទាឬសួរដេញដោលច្រើននោះដែរ គឺអាស្រ័យលើការចាត់ចែងរបស់នាយកសលា។

តាមរយៈការសម្ភាសន៍ ក្រុមសិស្ស ទាក់ទងនឹងសម្ភារ ពួកគេបាននិយាយថាៈ ពួកគេអត់មានសម្ភារ ឬ ឧបករណ៍ហាត់គ្រប់គ្រាន់នោះទេ ពោលគឺមានតែបាល់មួយឬពីរ ប៉ុន្នោះ ឯពេលខ្លះទៀតក៏គ្មានដែរ គឺហាត់តែទ្រឹស្តី និង ចលនាដៃជើង។សិស្សានុសិស្សនៅសាលាមួយបានបញ្ជាក់ថា ៖ ឆ្ងល់ណាស់ ថាពេលហាត់ក្នុងម៉ោងកីឡាទៅខ្វះសម្ភារ តែពួកគាត់ហាត់នៅម៉ោងជំនាញនឹងក៏ខ្វះដែរ ពួកកាត់អ្នកចូលចិត្តលេងត្រូវទិញខ្លួនឯង ហើយពេលទៅប្រកួតខ្វះការឧបត្ថម្ភខ្លាំង ត្រូវធ្វើដំណើរខ្លួនឯង ត្រូវចំណាយលុយលើការចូលរួម។

**ខ.បរិស្ថានសាលារៀន**

ក្រោយការចុះទៅសាកសួរនឹងអង្កេតនៅគ្រប់សាលាគោលដៅទាំងអស់នៅក្នុងស្រុកកៀនស្វាយ អ្នកស្រាវជ្រាវបានសង្កេតឃើញថាៈ អនុវិទ្យាល័យមួយក្នុងចំណោមអនុវិទ្យាល័យទាំងអស់មិនមានទីធ្លាកីឡា ឬបង្គលក្ខណៈសមស្របដល់ការកសាងទីធ្លាសម្រាប់អប់រំកាយ និងកីឡា ព្រោះបរិវេនតូចចង្អៀត។ រីឯ អនុវិទ្យាល័យផ្សេងទៀតកមិនខុសគ្នាដែរគឺថា មានទីធ្លា

សម្រាប់ហាត់អប់រំកាយ និងកីឡា ប៉ុន្តែអាចប្រើបាននៅចុងខែមករា នឹងដើមខែកុម្ភៈឯណោះ ព្រោះត្រូវទឹកលិច រងចាំរហូតដល់ទឹកស្រកអស់។លើសពីនេះអាចលិចទៅវិញនោះមិនទៀងទេ គឺអាស្រ័យលើមេឃភ្លៀងតិចឬច្រើន ពោលជាធម្មតាលិចនៅខែកញ្ញា។ បន្ថែមលើនេះទៀត នាពេលរដូវប្រាំងមានស្មៅដុសទ្រុបទ្រុល គ្មានការយកចិត្តទុកដាក់ថែរក្សាបានត្រឹមត្រូវ។ ចំណែកឯវិទ្យាល័យចំនួន៣មានបរិវេនអំណោយផលដល់អប់រំកាយ និងកីឡាក្នុងនោះមានសាលារៀន២ មានទីធ្លាកីឡាធំទូលាយ ប៉ុន្តែសាលាមួយមានស្មៅដុះទ្រុបទ្រុលនៅខែប្រាំង នឹងលិចទឹកនៅខែវស្សា ចាប់ពីខែមិថុនា ដល់ខែមករា ហើយមួយទៀតគ្រលីកគ្រលុក សុទ្ធតែដុំថ្ម។ ក្នុងចំណោមសាលាគោលដៅទាំងអស់មានសាលាមួយបានចាក់ដីបំពេញទីធ្លាកីឡាសម្រាប់បម្រើដល់វិស័យកីឡាផ្សេងៗ រីឯសាលាដទៃទៀតគឺនៅដដែល គ្មានការកែលម្អទេ។



## III. ទស្សនៈរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស

### ក.គណៈគ្រប់គ្រងសាលា

ឆ្លងតាមរយៈការចុះសម្ភាសន៍ជាមួយនាយកសាលាគោលដៅទាំងអស់ ក្នុងនោះមាននាយិកាមួយរូប ផងដែរ ទទួលបានព័ត៌មានដូចខាងក្រោម ៖

នាយកសាលាវិទ្យាល័យទាំងអស់បានលើកឡើងប្រហាក់ប្រហែលគ្នាថា៖

ពួកគាត់ចូលចិត្តវិស័យកីឡា ព្រោះជួយឲ្យសិស្សមានសុខភាពល្អ មានភាពអត់ធ្មត់ និងមានការសហការណ៍ ហើយសព្វថ្ងៃនេះក្មេងៗចូលចិត្តខ្លាំងណាស់ ហើយលើសពីនេះអប់រំកាយ និងកីឡាជាមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាទាំងអស់ដែលក្រសួងអប់រំ យុវជន និងកីឡាដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់ក្រសួង ដូចនេះយើងត្រូវតែអនុវត្តតាម។ ប៉ុន្តែបើយើងពិនិត្យលើការសម្ភាសន៍វិញនោះ យើងរកឃើញថា មុខវិទ្យាអប់រំកាយ និងកីឡា ត្រូវបាននាយយកសាលាវិទ្យាល័យគោលដៅទាំងអស់ដាក់នូវម៉ោងផ្សេងពីម៉ោងសិក្សា ពោលគឺបើម៉ោងសិក្សាទូទៅរៀនវេនព្រឹក ម៉ោងអប់រំកាយ និងកីឡានៅវេនរសៀល បើម៉ោងសិក្សានៅវេនរសៀល ម៉ោងអប់រំកាយនិងកីឡានៅពេលព្រឹក គឺមិននៅជាមួយនឹងម៉ោងរៀនទេ។ លើសពីនេះចំពោះថ្នាក់ទី ៩មានម៉ោងអប់រំកាយ និងកីឡាតែ ១ម៉ោង និងហាត់តែត្រឹមឆមាសទី១ បន្ទាប់មកគឺសម្រាក ចំណែកថ្នាក់ទី ១២ មានតែកាលវិភាគ តែគ្មានការអនុវត្តទេ ដោយហេតុថាពួកគាត់ត្រូវរៀនសម្រាប់ប្រលង។ បន្ថែមពីលើនេះទៀត ក្រោយការសម្ភាសន៍អ្នកស្រាវជ្រាវរកឃើញថា ម៉ោងអប់រំកាយ និងកីឡាត្រូវបានគេយកទៅធ្វើជាម៉ោងកសិកម្ម សម្អាតបរិស្ថាន ជំនួសឲ្យការហាត់ ។

នាយកសាលាវិទ្យាល័យមួយសូមមិនបញ្ចេញឈ្មោះ យល់ឃើញចំពោះគ្រូកីឡា និងមុខវិជ្ជាអប់រំកាយ និងកីឡាថា៖ វាជាបរិបទតំបន់ គាត់ហ៊ាននិយាអញ្ចឹងមានន័យថាវាសឹងតែដូចគ្នាទាំងអស់ដែលសាលាទាំងអស់មិនសូវយកចិត្តទុកដាក់លើមុខវិជ្ជាអប់រំកាយ និងកីឡា នៅក្នុងម៉ោងសិក្សាពោលគឺឲ្យតែមានក្រុមកីឡាទៅប្រកួតថ្នាក់ស្រុក ថ្នាក់ខេត្តទៅបានហើយ រីឯគ្រូកីឡា

វិញ សូមឲ្យតែមកតាមម៉ោងនឹងគ្រប់គ្រាន់ហើយ គាត់ក៏បានបន្ថែមទៀតថា ចំពោះសាលាគាត់បានផ្ដែកកីឡានឹងហើយជួយពង្រឹងវិន័យ អនាម័យ បរិស្ថានក្នុងសាលា គាត់ហាត់ខ្លះទៅ មិនហាត់ខ្លះទៅសំខាន់គាត់មកជួយវិន័យសាលា។

ចំពោះនាយកអនុវិទ្យាល័យគោលដៅទាំងអស់វិញ ក៏មិនខុសគ្នាដែរ ពួកគាត់បានលើកឡើងថា៖ពួកគាត់ចូលចិត្តវិស័យកីឡា ព្រោះជួយឲ្យសិស្សមានសុខភាពល្អ មានភាពអត់ធ្មត់ និងមានការសហការណ៍ ហើយសព្វថ្ងៃនេះក្មេងៗចូលចិត្តខ្លាំងណាស់ ហើយលើសពីនេះអប់រំកាយ និងកីឡាជាមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាទាំងអស់ដែលក្រសួងអប់រំ យុវជន និងកីឡាដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់ក្រសួង ដូចនេះយើងត្រូវតែអនុវត្តតាម។ ឆ្លងតាមការសម្ភាសន៍នាយកអនុវិទ្យាល័យ ភាគច្រើន អនុញ្ញាត ថ្នាក់ទី៩ ហាត់ត្រឹមឆមាសលើកទីមួយ ព្រោះទុកឲ្យសិស្សរៀនមុខវិជ្ជា ប្រលង។ លើសពីនេះគាត់បានយកម៉ោងកីឡា ធ្វើជាជាម៉ោង កសិកម្ម សម្អាតបរិស្ថាន ហើយក៏មិនដែលត្រួតពិនិត្យ រដ្ឋបាលគ្រូកីឡា យកគ្រូអប់រំកាយ និងកីឡាទៅបង្រៀនមុខវិជ្ជាផ្សេងៗថែមទៀតផង ។ នាយកសាលាមួយ ត្រូវបានរកឃើញថា៖ មិនអនុញ្ញាតឲ្យសិស្សានុសិស្សលេងកីឡានៅ ម៉ោងទំនេរទេ វាធ្វើឲ្យរំខានដល់សិស្សផ្សេងដែលកំពុងសិក្សារៀនសូត្រ។

**ខ.គ្រូបង្រៀន**

ឆ្លងតាមការសម្ភាសន៍ផ្ទាល់ យើបានរកឃើញនូវកត្តានិងទស្សនៈមួយចំនួនចំពោះគ្រូបង្រៀន មុខវិជ្ជាអប់រំកាយ និងកីឡាទាំង២១នាក់ នៅក្នុងសាលាគៅដៅទាំងអស់ក្នុស្រុងកៀនស្វាយ ។ក្នុងចំណោមគ្រូអប់រំកាយទាំងអស់ ដែលបានជួបសម្ភាសន៍ មានតែ៣នាក់ប៉ុណ្ណោះដែលចង់ធ្វើជាគ្រូអប់រំកាយ និងកីឡា ហើយមាន ៥នាក់ទៀតគាត់បានឆ្លើយថា៖ ពួកគាត់មិនចង់ក្លាយជាគ្រូកីឡាទេ ប៉ុន្តែដោយសាគ្មានជម្រើស ហើយមុខវិជ្ជានេះស្រួលជាងគេ ក្នុងចំណោមមុខវិជ្ជាដ៏ទៃទៀត។ចំណែកគ្រូអប់រំកាយដ៏ទៃទៀត បានលើកឡើងថា មូលហេតុដែលធ្វើជាគ្រូអប់រំកាយនិង កីឡាដោយសាតម្រូវចិត្តឳពុកម្តាយ និងគ្មានជម្រើស។ នេះសរបញ្ជាក់ថា ការជុំរុញទឹក

ចិត្តពីខាងក្នុងនោះរបស់ពួកគាត់អត់មានទេ ពួកគាត់ធ្វើតែតាមការៀបចំដោយគ្រូសារ។គ្មានការជុំរុញលើកទឹកចិត្ត គ្មានចំណង់ចំណូលចិត្ត ការងារក៏មិនរីកចម្រើនដែរគឺពួកគាត់គ្មានចិត្តធ្វើការទេ។

